លីកាដូ

LICADHO

# ស្ថានភាពអ្នកការពារ សិទ្ធិមនុស្សនៅកម្ពុជា

ខែ ធ្នូ ឆ្នាំ២០០៣

# ស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា
# របាយការណ៍ប្រចាំឆ្នាំរបស់លីកាដូ
# ខែធ្នូ ឆ្នាំ២០០៣

## បុព្វកថា

អង្គការលីកាដូត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ និងមានការិយាល័យនៅតាមបណ្តាខេត្តចំនួន១២ ទៀតនៃខេត្ត-ក្រុង២៤ ទូទាំងប្រទេស ។ ការងាររបស់លីកាដូជារួមមានការងារស៊ើបអង្កេតទៅលើករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះក្នុងការធ្វើបណ្តឹងទៅអាជ្ញាធរដែលពាក់ព័ន្ធ ធ្វើការស៊ើបអង្កេត និងតស៊ូមតិស្តីពីបញ្ហាសិទ្ធិមនុស្ស និងផ្តល់ការអប់រំសិទ្ធិមនុស្សដល់ក្រុមគោលដៅមួយចំនួន ។ ការងាររបស់លីកាដូត្រូវបានបែងចែកចេញជា ៦ ការិយាល័យរួមមានការិយាល័យអប់រំសិទ្ធិមនុស្សការិយាល័យការពារសិទ្ធិមនុស្ស ការិយាល័យការពារសិទ្ធិកុមារ ការិយាល័យការពារសិទ្ធិស្ត្រី ការិយាល័យពេទ្យ និងកម្មវិធីប្រឆាំងនឹងអំពើទារុណកម្ម ។

ឯកសារសង្ខេបនេះនឹងផ្តល់នូវទស្សនៈទូទៅនៃធាតុពិត និងការបន្តគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាដោយផ្អែកលើការស៊ើបអង្កេត និងការប្រមូលពតិមានដោយអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស (លីកាដូ)[១] ។

ឯកសារនេះ ផ្តោតទៅលើការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សដែលធ្វើការផ្ទាល់ក្នុងអង្គការសិទ្ធិមនុស្ស បុគ្គលិកទាំងឡាយដែលដោះស្រាយករណីរំលោភជាក់ស្តែងដែលជាផ្នែកមួយនៃគោលការណ៍របស់ពួកគេ ដោយរួមមានបុគ្គលិករបស់ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ឬសកម្មជនអង្គការ ឬសមាជិកបណ្តាញការងារ[២] ។

## សេចក្តីសង្ខេប

អ្នកការពារសិទ្ធិមនុស្សទទួលរងគ្រោះជាប្រចាំពីការគំរាមកំហែងនឹងបំភិតបំភ័យ ។ តាមពិតអំពើហិង្សាលើរូបរាងកាយហាក់ថយចុះទាបជាងកាលពីមុន ប៉ុន្តែនៅមានបុគ្គលិកសិទ្ធិមនុស្សមួយចំនួនកំពុងរស់នៅក្នុងភាពភ័យខ្លាចយ៉ាងខ្លាំងចំពោះអាយុជីវិតរបស់គេ ។ ករណីទាំងនេះហាក់ដូចជាកើនឡើងថែមទៀត នៅពេលដែល

---

[១] ការសំភាសន៍ជាមួយអ្នកស្រី សារ៉ា ខុម អង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ី-ព្រីធីស្ស អែតម៉ែន និង គាត បូផល បុគ្គលិកឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា អេវ៉ា ហ្កាឡេប្រូ អតីតនាយិការអង្គការឃ្លាំមើលព្រៃឈើ និងបុគ្គលិកផ្សេងៗទៀតនៅការិយាល័យស៊ើបអង្កេតលីកាដូ ។

[២] នៅក្នុងឯកសារនេះពាក្យ "**អ្នកការពារសិទ្ធិមនុស្ស**" ត្រូវបានប្រើប្រាស់មិនទូលំទូលាយពេកទេ ។ ពាក្យនេះមិនបានរួមបញ្ចូលសមាជិកគណបក្សនយោបាយទេ ដែលជំហរនយោបាយរបស់ពួកគេធ្វើអោយគេជួបប្រទះនូវគ្រោះថ្នាក់យ៉ាងខ្លាំង ។ ហើយក៏ពុំរួមបញ្ចូលអ្នកចូលរួមជាជនស៊ីវិលមួយចំនួន ដូចជា ព្រះសង្ឃ គ្រូបង្រៀន និងនិស្សិតដែលសកម្មក្នុងការងារជំរឿន និងការពារសិទ្ធិមនុស្ស ។

ការងាររបស់ពួកគេប៉ះពាល់ដល់ផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកដទៃ ។ សំខាន់ជាងនេះទៅទៀត ហាក់ដូចជាមានការកើនឡើងនូវការគំរាមកំហែងក្នុងរូបភាពលាក់កំបាំង ។

រហូតមកដល់ពេលនេះការរំលោភសិទ្ធិ និងការគំរាមកំហែងរួមទាំងអំពើឃាតកម្ម ការបង្ករបួសស្នាម ការគំរាមកំហែងដល់អាយុជីវិត ការគំរាមកំហែងដោយអំពើហិង្សាលើរូបរាងកាយ ការគំរាមកំហែងចាប់ចងដោយខុសច្បាប់ ការចាប់ដោយជាក់ស្តែង ការចោទប្រកាន់ដោយគ្មានភស្តុតាង និងការចាត់វិធានការណ៍ច្បាប់ដែលមានចេតនាបំភិតបំភ័យ ការគំរាមកំហែង ការឃ្លាំមើល និងការបំភិតបំភ័យតាមរូបភាពផ្សេងៗជាច្រើនទៀត ដែលទង្វើទាំងនេះជាគ្រោះថ្នាក់ដល់សុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេព្រមទាំងលទ្ធភាពក្នុងការអនុវត្តន៍ការងារប្រកបដោយសុវត្ថិភាព និងប្រសិទ្ធិភាពផង ។ នៅពេលដែលការបំភិតបំភ័យនេះត្រូវបានធ្វើឡើងជាចំហរវាបានធ្វើអោយប៉ះពាល់ដល់ជំនឿរបស់ប្រជាពលរដ្ឋទៅលើវិស័យសិទ្ធិមនុស្ស និងអ្នកការពារសិទ្ធិមនុស្ស ។

ប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ ការគំរាមកំហែងហាក់កើតមានច្រើនជាងអំពើហឹង្សា ដោយតាមរូបភាពបំភិតបំភ័យជាសំងាត់ផ្សេងៗទៀត អំពើហិង្សាទ្រង់ទ្រាយតូចដែលជារូបភាពនៃការបំភិតបំភ័យបានក្លាយជារឿងធម្មតាទៅហើយ ការលួចថតរូបបុគ្គលិកការពារសិទ្ធិមនុស្ស ការសួរចំលើយអំពីសមាជិកគ្រួសាររបស់ពួកគេ និងជាពិសេសការគំរាមចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ទោះបីជាមិនទំនងថាបានឈ្នះតាមផ្លូវច្បាប់ក៏ដោយ ក៏វាបានធ្វើអោយបុគ្គលិកសិទ្ធិមនុស្សរងគ្រោះដោយការឃុំឃាំង ផ្តាច់ការទាក់ទងក្នុងពន្ធនាគារដែលគួរអោយភ័យខ្លាច ។ កន្លងមកក៏មានការចាប់ចងបែបនេះផងដែរ ។ មានការកើនឡើងនូវការគំរាមកំហែងជារូបភាព ការចាត់វិធានការណ៍ច្បាប់ ដូចជាការប្តឹងពីបទបរិហាកេរ្តិ៍ទារសំណងជំងឺចិត្ត ដែលធ្វើអោយគាំងដំណើរការងាររបស់អង្គការ ។

ការផ្លាស់ប្តូរដោយប្រើស្នៀតប្រសើរជាងមុនយ៉ាងប៉ិនប្រសប់ គឺដើម្បីបង្ហាញអោយឃើញថាគេបានយកចិត្តទុកដាក់នូវការតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ប៉ុន្តែទង្វើនេះបានត្រឹមតែពោលអោយរួចពីមាត់តែប៉ុណ្ណោះ ។ ការប៉ុនប៉ងប្រើសិទ្ធិអំណាច ដើម្បីកំណត់សេរីភាពនៃការប្រជុំដោយលើកយកលេសឥតសមហេតុផល និងមិនសមស្របតាមបញ្ហាសន្តិសុខ ប៉ុន្តែនេះជាការអនុវត្តន៍ដោយឥតអៀនខ្មាស់ ដោយអំពើហិង្សាយ៉ាងធ្ងន់ធ្ងរ សូម្បីតែនៅពេលមិនទំនងជាមានការគំរាមកំហែងដល់សន្តិសុខក៏ដោយ រដ្ឋអំណាចកម្ពុជាបានបដិសេធជាអលជ្ជីរាល់សំណើស្នើសុំដើម្បីប្រមូលផ្តុំគ្នាដោយសន្តិវិធី ហើយបានវាយដេញបំបែករាល់ការប្រមូលផ្តុំទាំងឡាយ ដោយប្រើអំពើហិង្សាហួសប្រមាណដោយមិនស្របតាមស្ថានការណ៍នៅទីនោះឡើយ ឬក៏បង្ហាញតាមរូបភាពគំរាមកំហែងបែបសន្តិវិធី ។ នៅខែ ឧសភា ឆ្នាំ២០០៣ សំណើរបស់គណៈកម្មាធិការស្ត្រីកម្ពុជាមួយត្រូវបានបដិសេធលើសំណើស្នើសុំអោយក្រុមស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារជួបជុំគ្នា ដើម្បីជ្រើសរើសតំណាងរបស់ខ្លួនអោយមកចូលរួមជជែកពិភាក្សាលើពង្រាងច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ។ នៅខែមិថុនា ឆ្នាំ២០០៣ ការស្នើសុំដើរជាក្បួន ដើម្បីអបអរទិវាបរិស្ថានពិភពលោកក៏ត្រូវបានរដ្ឋអំណាចបដិសេធផងដែរ ។

ស្រដៀងគ្នានេះដែរ ការគំរាមចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌបានបង្ហាញនូវចេតនាគោរពច្បាប់តែសំបកក្រៅ ផ្ទុយវិញទៅគ្រាន់តែជាការបំភាន់ភ្នែកតែប៉ុណ្ណោះហើយទង្វើនេះជាការបំភិតបំភ័យដល់បុគ្គលិកអង្គការគ្រប់លំដាប់ថ្នាក់ចំពោះការងារស្របច្បាប់របស់ពួកគេ ។ បើនិយាយអំពីតុលាការវិញ គឺល្បីល្បាញខាងអំពើពុករលួយនឹងរងនូវសំពាធឥទ្ធិពលពីខាងក្រៅ ទោះបីជារឿងក្តីដែលមើលទៅថាគ្មានសង្ឃឹមក៏នៅតែទទួលរងនូវការគំរាមកំហែងដែរ ។ បញ្ហាពាក់ព័ន្ធដ៏សំខាន់មួយគឺទាក់ទងនឹងអង្គការមិនមែនរដ្ឋាភិបាលដែលមានចរិតនយោបាយគាំទ្ររដ្ឋាភិបាល ។ អង្គការទាំងនេះមិនគំរាមផ្ទាល់ដល់បុគ្គលិក ឬអង្គការសិទ្ធិមនុស្សទេ ប៉ុន្តែបានបង្ហាញអោយឃើញថា រដ្ឋាភិបាលមានកម្មវិធីសិទ្ធិមនុស្សសកម្មមួយនឹងមានទំនាក់ទំនងដែលមានស្រាប់ជាមួយសហគមន៍សិទ្ធិមនុស្សអន្តរជាតិ តែតាមការពិតគេបានបង្កើតនូវរបៀបវារៈដោយខ្លួនគេ ហើយច្រើនលើកច្រើនសារបានបដិសេធទាត់ចោលនូវរបាយការណ៍សិទ្ធិមនុស្សនានា និងបង្ករឧបសគ្គដល់សកម្មភាពរបស់អង្គការសិទ្ធិមនុស្សដែលត្រឹមត្រូវទៀតផង ។

រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានទាមទារអោយផ្តន្ទាទោសជនល្មើសទាំងអស់ ។ ការរំលោភប្រព័ន្ធច្បាប់ដែលជាមធ្យោបាយមួយ ដើម្បីរារាំងនឹងបំភិតបំភ័យបុគ្គលិកអង្គការសិទ្ធិមនុស្សត្រូវតែឈប់ជាបន្ទាន់ ។ ដោយលើកយកការរំលោភអំណាចលើស្ថាប័នដែលបានឈានដល់កំរិតកំពូលនោះ តំរូវអោយមានការខិតខំព្រមៗគ្នាមួយរវាងអង្គការសិទ្ធិមនុស្ស ទីភ្នាក់ងារផ្តល់ជំនួយ និងរដ្ឋាភិបាលបរទេស ដើម្បីបង្ខំអោយរដ្ឋាភិបាលផ្តល់ដល់ប្រជាពលរដ្ឋកម្ពុជា និងអ្នកដែលព្យាយាមការពារសិទ្ធិមនុស្សនូវសិទ្ធិដ៏ពិតប្រាកដជាជាងសិទ្ធិដ៏ស្ងួតស្ងើង ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវបានអំពាវនាវអោយប្រកាន់ខ្ជាប់នូវ ***សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គមស៊ីវិល ដើម្បីជំរុញនឹងការពារសិទ្ធិ រួមទាំងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ជាសកល[៣] ។***

## ប្រវត្តិសិទ្ធិមនុស្សនៅកម្ពុជា

សង្គមកម្ពុជាកំពុងតស៊ូឆ្លងកាត់ដល់ដំណាក់កាលមួយដែលជាមតិកដ៏ព្រៃផ្សៃនៃរបបប៉ុលពត ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ដែលក្នុងសម័យនោះមានជនកម្ពុជាប្រមាណ ១.៧ លាននាក់បានស្លាប់ ។ ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរត្រូវបានប្រព្រឹត្តិនៅទូទាំងប្រទេស ដោយរួមមានការធ្វើទារុណ្ណកម្ម កាប់សំលាប់ បង្ខំអោយធ្វើពលកម្មជាទំងន់ បង្អត់អាហារ និងការរំលោភសេពសន្ថវៈ ។ បញ្ញវ័ន្តភាគច្រើនបានស្លាប់ដោយមិនបានបន្សល់ទុកនូវមនុស្សដែលមានការអប់រំដើម្បីគ្រប់គ្រងសង្គមស៊ីវិលឡើយ ។ ទោះបីជារបបខ្មែរក្រហមបានបញ្ចប់នៅឆ្នាំ ១៩៧៩ ទៅហើយក្តី ក៏សង្គ្រាមស៊ីវិលនៅបន្តរហូតមកដល់ចុងទស្សវត្សឆ្នាំ១៩៩០ ដែលនៅពេលនោះគណបក្សនយោបាយ

---

[៣] ឯកសារយោងរបស់អង្គការសហប្រជាជាតិ A/RES/53144 ខែ មិនា ឆ្នាំ ១៩៩៩ អាចស្រាវជ្រាវតាមអាសយដ្ឋាន http//www.unhchr.ch/huidocda/huridoca.nsf/(Symbol)/A.RES.53.144.En?OpenDocument

ផ្សេងៗបានចូលរួមប្រកួតដណ្តើមអំណាចគ្នា ។ ការបង្កើតអ៊ុនតាក់ក្នុងឆ្នាំ១៩៩២ បានបង្ករលក្ខណៈដល់ការលេចឡើង និងការស្តាបនាសង្គមស៊ីវិលឡើងវិញ ។

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដំបូងគឺសមាគមអាដហុក និងអង្គការលីកាដូ ដែលចាប់ផ្តើមប្រតិបត្តិការក្នុងពេលដ៏ខ្លីក្រោយពីមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនៅក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ ។ ទាំងអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងអន្តរជាតិបានបន្តនូវតួនាទីដ៏ធំធេងរបស់ខ្លួនក្នុងកិច្ចការពារជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស ដោយបានផ្តល់នូវសេវាជាមូលដ្ឋាន ដូចជាម្ហូបអាហារ ជំរកស្នាក់នៅ ជំនួយវេជ្ជសាស្ត្រ ការតស៊ូមតិនឹងកិច្ចការពារតាមផ្លូវច្បាប់ ។ អង្គការមិនមែនរដ្ឋាភិបាលក៏បានអនុវត្តន៍នូវការងារសង្គមស៊ីវិលដ៏សំខាន់ផងដែរ ដូចជា ការឃ្លាំសង្កេតមើលស្ថាប័នរដ្ឋាភិបាលមួយចំនួន និងការរិះគន់ទិសៀនគោលនយោបាយជាផ្លូវការ ដែលមិនបានអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ។ ក្រុមអង្គការសិទ្ធិមនុស្សនៅកម្ពុជាបានបន្តយ៉ាងសកម្ម ដែលរួមមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកប្រមាណ ៨០០ និងអង្គការអន្តរជាតិប្រមាណ ១៥០ ទៀតដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃរហូតមកទល់ឆ្នាំ ២០០៣[៤] ។

## ឧបសគ្គបច្ចុប្បន្នដែលសង្គមស៊ីវិលនៅកម្ពុជាកំពុងប្រឈមមុខ

ភាពក្រីក្រគឺជាចំណោទមួយដ៏ធំនៅកម្ពុជា ដែលផលទុនជាតិក្នុងប្រជាជនម្នាក់ត្រឹមតែ ២៨៥ ដុល្លា តែប៉ុណ្ណោះ[៥] ។ ជាលទ្ធផល ប្រជាពលរដ្ឋមានកំរិតជីវិភាពរស់នៅយ៉ាងទាបបំផុត ស្ថានភាពសុខភាពដ៏យ៉ាប់យ៉ឺន និងមានអត្រាអាយុរស់នៅសង្ឃឹមទុកត្រឹមតែ៥៤ឆ្នាំតែប៉ុណ្ណោះ[៦] ។ លើសពីនេះទៅទៀតភាពក្រីក្រនេះបានបង្ករអោយមានបញ្ហាដែលមើលមិនឃើញថែមទៀត និងជាឧបសគ្គរារាំងដល់សង្គមស៊ីវិលក្នុងការងារពេលបច្ចុប្បន្ន ។ តុលាការនិងប៉ូលីសនៅខ្សោយនៅឡើយ ជាពិសេសកង្វះខាតមូលនិធិ ការហ្វឹកហ្វឺនជំនាញ ព្រមទាំងធនធានគ្រប់មុខទាំងអស់ ។ មានអំពើពុករលួយយ៉ាងធ្ងន់ធ្ងរនៅគ្រប់ជាន់ថ្នាក់ទាំងអស់ ហើយថែមទាំងទទួលរងនូវឥទ្ធិពលពីផ្នែកប្រតិបត្តិរបស់រដ្ឋបាលទៀតផង ។ កងកំលាំងប៉ូលីស និងទាហ៊ានជាអ្នកទទួលខុសត្រូវលើករណីឃាតកម្មជាច្រើន ដែលត្រូវបានស៊ើបអង្កេតនឹងចងក្រងជាឯកសារជារៀងរាល់ឆ្នាំទាំងករណីនយោបាយ និងករណីមិនទាក់ទងនយោបាយ ។ លើសពីនេះទៅទៀត រដ្ឋាភិបាលបានគ្រប់គ្រងនឹងត្រួតពិនិត្យប្រព័ន្ធឃោសនាមួយភាគធំ ។ ការជំទាស់នឹងតវ៉ាមិនត្រូវបានសណ្តោសប្រណីឡើយ ។ ប្រជាពលរដ្ឋកម្ពុជាខ្វះជំនឿជឿជាក់ចំពោះសិទ្ធិមនុស្សដូច្នេះហើយក៏ពុំមានជំនឿក្នុងការទាមទារអោយមានសិទ្ធិនោះផងដែរ ។

កត្តាទាំងនេះ គួបផ្សំជាមួយនឹងកង្វះសុឆន្ទៈនយោបាយក្នុងការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស កង្វះការហ្វឹកហ្វឺនដល់អាជ្ញាធររដ្ឋាភិបាល និងកង្វះការទទួលខុសត្រូវជាលទ្ធផលនាំអោយមានអំពើពុករលួយ និងនិទ្ទណ្ឌ

---

[៤] គណៈកម្មការដើម្បីសហប្រតិបត្តិការកម្ពុជា " មគ្គុទេសន៍ដើម្បីជំនួយអភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០០៣-២០០៤ ។

[៥] ស្ថិតិរបស់ធនាគារពិភពលោកឆ្នាំ ២០០២ ។

[៦] ស្ថិតិធនាគារពិភពលោក ឆ្នាំ ២០០២ ។

ភាពជាទូទៅ ។ កង្វះការយោគយល់ និងការទទួលស្គាល់ក្រុមសិទ្ធិមនុស្ស ព្រមទាំងសកម្មភាពដ៏សំខាន់របស់ពួកគេពីសំណាក់អាជ្ញាធររដ្ឋាភិបាលជាន់ខ្ពស់ គឺជាការរួមចំណែកថែមទៀតក្នុងបរិយាកាស ដែលកិច្ចការពារជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សបានក្លាយទៅជាកិច្ចការមួយដែលប្រកបដោយគ្រោះថ្នាក់ទីបំផុត ។

## ការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្ស

ពត៌មានពីអង្គការលីកាដូ និងអង្គការសិទ្ធិមនុស្សផ្សេងៗទៀតបានបង្ហាញនូវគំរូហិង្សាមួយយ៉ាងច្បាស់ គឺការគំរាមកំហែង និងការបំភិតបំភ័យមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ។ បញ្ហានេះបានបន្ថែមនូវកង្វល់ដ៏ធំមួយអំពីស្ថេរភាពនឹងនិរន្តន៍ភាពដ៏យូរអង្វែងនៃការងារសិទ្ធិមនុស្ស ។

កាលពីប្រាំឆ្នាំកន្លងទៅការគំរាមកំហែង និងការបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្សរួមមានដូចជាអំពើឃាតកម្ម ការគំរាមកំហែងដល់អាយុជីវិត ការដុតបំផ្លាញលំនៅដ្ឋាន ការបង្ករបួសស្នាម និងការគំរាមបង្ករអោយមានរបួសស្នាម ការចាប់ដាក់ពន្ធនាគារ និងការគំរាមចាប់ខ្លួនដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងចាត់វិធានការណ៍ច្បាប់មិនស្របតាមនិតិវិធីទាំងបទល្មើសព្រហ្មទណ្ឌ និងរដ្ឋប្បវេណីយ៍ដោយប៉ូលីស និងអាជ្ញាធររដ្ឋដែលរៀបចំឡើងដើម្បីបំភិតបំភ័យដោយលិខិតព្រមានការគំរាមតាមទូរស័ព្ទ ការឃ្លាំមើល តាមដានដោយចំហរ និងការឃ្លាំមើលសកម្មភាពក៏ដូចជាការបំភិតបំភ័យតាមរូបផ្សេងៗជាច្រើនទៀត ប្រព្រឹត្តិមកលើជនស៊ីវិលនិងអតិថិជនរបស់អ្នកការពារសិទ្ធិមនុស្សជាដើម[៧] ។

ជនល្មើសដែលបង្ករការគំរាមកំហែងទាំងនោះរួមមានជនស៊ីវិល ប៉ូលីស មន្ត្រីយោធា មន្ត្រីឃុំ ប្រធានមន្ទីរតាមបណ្តាខេត្ត/ក្រុង អាជ្ញាធរស្រុក មន្ត្រីស៊ុរិយោដីស្រុក អភិបាលស្រុក និងអាជ្ញាធរប៉ូលីសរបស់ពួកគេព្រមទាំងមន្ត្រីតុលាការផងដែរ ។

ជនរងគ្រោះរួមមានបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ និងពួកអ្នកដែលគ្រាន់តែផ្តល់សំភារៈគាំទ្រដល់អ្នកទាំងនោះ ។ សូម្បីតែតំណាងរបស់អង្គការសហប្រជាជាតិក៏រងការគំរាមកំហែង និងការរំលោភផងដែរ ។ ជាលទ្ធផល អង្គការមួយចំនួនបានផ្អាកកិច្ចប្រតិបត្តិការលើវិស័យការងារ និងអង្គការមួយចំនួនទៀត ត្រូវគំរាមអោយដកចេញ ហើយនៅក្នុងផ្ទៃកខ្លះសមាជិកសហគមន៍បានបង្ហាញនូវសញ្ញាស្ទាក់ស្ទើរក្នុងការបន្តធ្វើការងារជាមួយអ្នកការពារសិទ្ធិមនុស្សផងដែរ ។

## អំពើឃាតកម្មដោយហិង្សា

នៅឆ្នាំ ១៩៩៨ សកម្មជនអាដហុកម្នាក់នៅខេត្តកណ្តាលត្រូវបាញ់សំលាប់ ក្នុងខណៈកំពុងធ្វើជាតំណាងអោយប្រជាពលរដ្ឋ ១៤គ្រួសារ ដែលត្រូវគំរាមបណ្តេញចេញពីដីធ្លី និងផ្ទះសម្បែងរបស់ពួកគេ ។ ជនល្មើសម្នាក់

---

[៧] ពត៌មានបន្ថែម សូមមើលតារាងខាងក្រោយស្តីពីរបាយការណ៍នៃការវាយប្រហារ ការគំរាមកំហែង និងការបំភិតបំភ័យមកលើអ្នកការពារសិទ្ធិមនុស្ស ។

ត្រូវបានចាប់ខ្លួន ហើយក្រោយមកក៏ត្រូវបានតុលាការដោះលែងនៅឆ្នាំ១៩៩៩ ។ បុគ្គលិកសិទ្ធិមនុស្សបានអះអាងថា អំពើពុករលួយក្នុងជួរយោធា និងប៉ូលីសបានបង្ករការរាំងស្ទះដល់ការស៊ើបអង្កេត និងការសាកសួរពត៌មានផ្សេងៗ ។

នៅខែធ្នូ ឆ្នាំ២០០២ តំណាងបណ្ដាញសហគមន៍រុក្ខាម្នាក់អាយុ ២៩ឆ្នាំ បានស្លាប់ភ្លាមៗ ក្រោយពីការទាមទារដោយសន្ដិវិធីត្រូវបានវាយបំបែកដោយប៉ូលីស និងយោធាដែលមានកងកំលាំងច្រើនហួសហេតុ ដោយប្រើប្រាស់អាវុធ ដូចជាដំបងឆក់ជាដើម ។ គ្រូពេទ្យជំនាញរដ្ឋ និងគ្រូពេទ្យជំនាញឯកជនមិនអាចបង្ហាញអោយឃើញនូវមូលហេតុជាក់ស្ដែង ដែលជាហេតុនៃការស្លាប់របស់យុវជននោះទេ ។ មនុស្សគ្រប់រូបបានដឹងថា ដំបងឆក់អាចបណ្ដាលអោយមានរបួសធ្ងន់ធ្ងរ និងស្លាប់តាមរយៈការគាំងបេះដូង[៨] ។ វេជ្ជបណ្ឌិតនៅមន្ទីរពេទ្យព្រះកុសមៈបាននិយាយថា ការស្លាប់របស់យុវជននោះគឺបណ្ដាលមកពីការគាំងបេះដូង[៩] ។

ការគំរាមកំហែងដល់អាយុជីវិតដែលបានរាយការណ៍ដោយអ្នកការពារសិទ្ធិមួយចំនួន។ នៅក្នុងឆ្នាំ ២០០២ មានអ្នកការពារសិទ្ធិមនុស្សបានដឹងនូវតំលៃដែលគេហ៊ានអោយជារង្វាន់ក្នុងការសំលាប់រូបនាង ។

## ការវាយដំលើរាងកាយ និងការគំរាមបង្ករបួសស្នាម

ការវាយដំលើរាងកាយនៅតែជាទំរង់នៃការបំភិតបំភ័យមួយដែលប្រព្រឹត្តិទូទៅជាទីបំផុត។

នាយកនៃអង្គការឃ្លាំមើលព្រៃឈើឯករាជ្យមួយ គឺអង្គការក្លូបូលវីតណេសត្រូវបានរងការវាយដំ និងទាត់ធាត់យ៉ាងដំណំដោយជនបិទមុខពីរនាក់នៅជិតការិយាល័យរបស់នាង ។ ក្រោយពីការរំលោភបំពានរាងកាយនេះក៏មានលិខិតសារតាមអ៊ីមែលមកគំរាមដោយសរសេរតែពាក្យមួយម៉ាត់ថា "***ឈប់***" ។ ក្រោយមកទៀត នាងក៏រងនូវការគំរាមកំហែងដល់អាយុជីវិតថែមទៀត ។ គេជឿថារឿងនេះជាអំពើមួយដែលទាក់ទងទៅ និងរបាយការណ៍របស់ក្លូបូលវីតណេសអំពីការកាប់ឈើខុសច្បាប់ និងការពាក់ព័ន្ធរបស់មន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល ។ ***សូមអានរបាយការណ៍ករណីបន្ថែមក្នុងទំព័រខាងក្រោយ។***

## ការគំរាមដោយពាក្យសំដី

សូរនៃការគំរាមកំហែងដោយពាក្យសំដីក៏នៅតែជាយុទ្ធសាស្ត្រនៃការបំភិតបំភ័យមួយ ។ ភាគច្រើនជនល្មើសដែលប្រព្រឹត្តិអំពើទាំងនេះគឺជាជនអនាមិក ហើយមិនអាចរកឃើញទេ ។

---

[៨] សេចក្ដីថ្លែងការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅកម្ពុជា ស្ដីពីការប្រើកំលាំងជ្រុលហួសហេតុដោយមន្ត្រីអនុវត្តច្បាប់ នៅថ្ងៃទី ៩ ខែ ធ្នូ ២០០២ ។

[៩] របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ី-កម្ពុជាៈ ការប្រើកងកម្លាំងច្រើនហួសហេតុប្រឆាំងនឹងក្រុមសហគមន៍រក្សាព្រៃឈើ ។

ការនិយាយជាសាធារណៈអំពីកិច្ចការរបស់អ្នកការពារសិទ្ធិមនុស្ស ក៏ជារូបភាពនៃការគំរាមកំហែងដោយពាក្យសំដីមួយដែរ ។ នាយករដ្ឋមន្ត្រីផ្ទាល់បានប្រើប្រាស់នូវភាសាគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្សជាច្រើនលើកច្រើនដង ។ នៅក្នុងខែធ្នូ ឆ្នាំ២០០០ នាយករដ្ឋមន្ត្រីបានចោទប្រកាន់អង្គការសិទ្ធិមនុស្សថា "***លាក់បំពួនភេរវៈជនអោយជ្រកក្រោមផ្លាកសិទ្ធិមនុស្ស***" បន្ទាប់មកក៏មានការគំរាមកំហែងដាក់គុកអ្នកការពារសិទ្ធិមនុស្សទៀតដោយនិយាយថា "***យើងនឹងដាក់ខ្នោះ អ្នកឯងដោយមិនបានគិតថាអ្នកនោះជាអ្នកការពារសិទ្ធិមនុស្សឡើយ... ប្រសិនបើមានពាក់ព័ន្ធនោះនឹងត្រូវចាប់ខ្លួន***" នៅខែធ្នូ ឆ្នាំ២០០២ ឆ្លើយតប ទៅនឹងការរិះគន់របស់អង្គការក្លូបូលវីតណេស នាយករដ្ឋមន្ត្រីបាននិយាយថា "***យើងមានសិទ្ធិបញ្ចប់ទិដ្ឋាការ របស់នរណាម្នាក់... ដែលហ៊ានរំលោភលើអធិបតេយ្យភាពជាតិ សិទ្ធិនយោបាយរបស់យើង និងការបរិហារកេរ្តិ៍យើង***" ។

ភាសាគំរាមកំហែងដែលចេញមកពីមន្ត្រីកំពូលនៃរដ្ឋាភិបាលក្នុងប្រទេស បានបង្កើតអោយមានការគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្ស ព្រមទាំងបន្តអោយមានគ្រោះថ្នាក់ដល់សុវត្ថិភាពរបស់អ្នកទាំងនោះនាពេលអនាគតទៀតផងដែរ ។

## ការចាប់ខ្លួនឃុំឃាំង និងការគំរាមចាប់ខ្លួនដាក់ពន្ធនាគារដោយបំពាន

អ្នកការពារសិទ្ធិមនុស្សជាតិ និងអន្តរជាតិមិនទាន់ស៊ាំនឹងបញ្ហាឃុំឃាំងដោយខុសច្បាប់ ដែលកើតមានគ្រប់ទិសទីនោះទេ ។ នៅឆ្នាំ១៩៩៨ បុគ្គលិកអង្គការលីកាដូ ២ នាក់ ត្រូវបានចាប់ខ្លួន ដោយការចោទប្រកាន់ និងឃុំឃាំងក្នុងពន្ធនាគារអស់រយៈពេលមួយខែ ក្រោយពីបុគ្គលិកទាំង២នាក់នេះបានឃ្លាំមើលបាតុកម្មប្រឆាំងនឹងចាក់កាកសំណល់ដែលមានជាតិពុលនៅក្រុងព្រះសីហនុ ។ ករណីស្រដៀងគ្នានេះមួយទៀតមាននៅខែមិនា ឆ្នាំ ២០០០ បុគ្គលិកអង្គការលីកាដូដែលបានជួយកម្មកររោងចក្រកាត់ដេរ ដែលត្រូវគេជួញដូរពីប្រទេសវៀតណាមក៏ទទួលរងការគំរាមកំហែងរកចាប់ខ្លួនដែរ ។ សូម្បីតែមនុស្សដែលពុំមែនជាបុគ្គលិកសិទ្ធិមនុស្ស ឬបុគ្គលិកអង្គការសហប្រជាជាតិក៏ទទួលរងគ្រោះដែរ ដូចជានៅក្នុងខែមិនា ឆ្នាំ២០០២ អ្នកបើកកាណូត ម្នាក់ដែលជួលដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ដើម្បីដឹកជញ្ជូនជនជាតិភាគតិចភៀសខ្លួនក៏ត្រូវបានចាប់ខ្លួននឹងត្រូវបានចោទប្រកាន់ពីបទជួញដូរមនុស្ស ។ ក្រោយមកនៅថ្ងៃទី១២ ខែសីហា ក៏ត្រូវបានដោះលែងក្រោយការឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេល ៤ ខែរួចមក ។

បើពិនិត្យមើលរបាយការណ៍ស្ដីពីការធ្វើទារុណកម្មនៅក្នុងមន្ទីរឃុំឃាំងរបស់ប៉ូលីស ស្ថានភាពដ៏យ៉ាប់យ៉ឺនក្នុងពន្ធនាគារកម្ពុជា និងការអនុវត្តន៍ការឃុំឃាំងលើសនិតិវិធីជាទូទៅ (លើសរយៈពេល ៦ ខែ ដែលកំណត់ដោយច្បាប់កម្ពុជា) ការគំរាមចាប់ខ្លួនឃុំឃាំងតាមអំពើចិត្តការឃុំឃាំងដោយផ្ដាច់ការទាក់ទងពិតជាគ្រោះថ្នាក់ដោយ

ហេតុផលអំពើទារុណ្ណកម្ម ជាមិនខាន[១០] ។

## ការគំរាមចាត់វិធានការណ៍ផ្លូវច្បាប់ដើម្បីគោលបំណងបំភិតបំភ័យ

អង្គការសិទ្ធិមនុស្ស ដែលឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ត្រូវរងការគំរាមកំហែងកាន់តែច្រើនឡើងៗពីចំណាត់ការច្បាប់ដោយមិនសមហេតុផលដែលធ្វើឡើងដើម្បីគោលបំណងបំភិតបំភ័យ ។ តាមបទពិសោធន៍សាមញ្ញរបស់អង្គការមិនមែនរដ្ឋាភិបាលនោះគេកាន់តែមានការបារម្ភថែមទៀត ចំពោះការចាត់វិធានការណ៍ច្បាប់ ដែលមិនសមស្របទាំងករណីព្រហ្មទណ្ឌ និងករណីរដ្ឋប្បវេណីយ៍ដែលបានប្តឹងបុគ្គលិកអង្គការសិទ្ធិមនុស្សដើម្បីជាការបំភិតបំភ័យ និងបំបាក់ទឹកចិត្តក្នុងការបន្តអនុវត្តន៍ការងាររបស់ពួកគេ ។ ដោយលើកយកតែការអនុវត្តន៍ពីការឃុំខ្លួនបណ្តោះអាសន្ន និងស្ថានភាពពន្ធនាគារដ៏គួរខ្លាចនោះ វាជាការគំរាមកំហែងមួយដ៏ធ្ងន់ធ្ងរណាស់ទៅហើយ[១១] ។ ការស្ទាក់ស្ទើររបស់តុលាការក្នុងការលើកលែងការចោទប្រកាន់ ដែលមិនត្រឹមត្រូវបានបញ្ចេញនូវភាពលំអៀង និងអំពើពុករលួយរបស់តុលាការគឺជាការបន្ថែមលើការបំភិតបំភ័យដល់បុគ្គលិកសិទ្ធិមនុស្សមួយកំរិតថែមទៀត ។

ក្នុងខែ ឧសភា ឆ្នាំ ២០០១ តុលាការក្រុងភ្នំពេញបានចោទប្រកាន់នាយកស្តីទីនៃអង្គការលីកាដូពីបទឃុំឃាំងមនុស្សខុសច្បាប់ ។ ករណីនេះពាក់ព័ន្ធទៅនឹងការជួយសង្គ្រោះកុមារី អាយុ៧ឆ្នាំម្នាក់ ដែលត្រូវម្តាយចិញ្ចឹមរបស់នាងវាយដំយ៉ាងធ្ងន់ធ្ងរ ហើយប៉ូលីសបានប្រគល់នាងអោយអង្គការលីកាដូដើម្បីថែទាំនឹងគ្រប់គ្រងដោយស្របច្បាប់ជាបណ្តោះអាសន្ន ។ ឪពុកម្តាយចិញ្ចឹមរបស់ជនរងគ្រោះបានប្តឹងនាយកស្តីទីលីកាដូពីបទឃុំឃាំងមនុស្សខុសច្បាប់នឹងចាប់ជំរិត ។ ទោះបីជាក្រោយមកឪពុក-ម្តាយចិញ្ចឹមនោះត្រូវបានកាត់ទោសពីបទរំលោភលើរូបរាងកាយ និងបង្កររបួសស្នាម ហើយលីកាដូត្រូវបានអនុញ្ញាតអោយគ្រប់គ្រងកុមារីរងគ្រោះជាបណ្តោះអាសន្នបន្ត និងក្រោយមកគ្រប់គ្រងអចិន្ត្រៃយ៍ដោយតុលាការដដែលក្តី ប៉ុន្តែព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតនៅតែមិនលើកលែងការចោទប្រកាន់ដែលប្តឹងដោយឪពុក-ម្តាយចិញ្ចឹមនោះទេ បែរជាឯកភាពលើការចោទប្រកាន់ពីបទល្មើសឃុំឃាំងមនុស្សខុសច្បាប់ទៅវិញ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ីបានរាយការណ៍ថា ***"ក្រុមអង្គការសិទ្ធិមនុស្សកម្ពុជា និងអន្តរជាតិបានសំដែងនូវការព្រួយបារម្ភចំពោះបណ្តឹង ដោយពុំមានមូលដ្ឋានជាក់លាក់ក្រៅពីធ្វើអោយមានការបំភិតបំភ័យដល់អង្គការលីកាដូច្រើនដង"***[១២] ។ ក្រោយមកនាយកស្តីទីលីកាដូ បានដឹងទៀតថាចៅក្រមស៊ើបអង្កេតមានចេតនាចង់ចាប់នាងដាក់ពន្ធនាគារ ។ ទីបំផុតចៅក្រមស៊ើបអង្កេតបានលើកលែងការចោទប្រកាន់ពីបទឃុំ

---

[១០] តាមច្បាប់កម្ពុជា ការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវលើសពី ៤ ខែទេ ។ តាមច្បាប់ព្រហ្មទណ្ឌអន្តរកាល ក្នុងមាត្រា១៤ បានចែងថា ការឃុំខ្លួនបណ្តោះអាសន្ន ៦ ខែ ត្រូវបានអនុញ្ញាតតែក្នុងពិសេសប៉ុណ្ណោះ ។ ប៉ុន្តែតាមការស៊ើបអង្កេតរបស់អង្គការលីកាដូបង្ហាញអោយឃើញថា អាជ្ញាធរមានសមត្ថកិច្ចជាធម្មតាមិនបានគោរពតាមពេលវេលាកំណត់នេះទេ ។ ចំពោះពត៌មានផ្សេងៗទៀត ដែលទាក់ទងទៅនឹងស្ថានភាពពន្ធនាគារកម្ពុជា សូមអានរបាយការណ៍ស្តីអំពីសិទ្ធិមនុស្ស និងពន្ធនាគារកម្ពុជា របាយការណ៍ប្រចាំឆ្នាំ ២០០២ របស់លីកាដូស្តីពីសិទ្ធិមនុស្ស និងស្ថានភាពសុខភាពរបស់ទណ្ឌិត និងពិរុទ្ធជនក្នុងពន្ធនាគារកម្ពុជា ដែលចេញផ្សាយនៅឆ្នាំ២០០២ ។

[១១] ឯកសារដដែល ។

[១២] របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស-ធនាគារពិភពលោក ឆ្នាំ២០០១

ឃាំងមនុស្សខុសច្បាប់ ។ នៅពេលនោះ ឪពុក-ម្តាយចិញ្ចឹមនៅបន្តប្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសំរេចរបស់តុលាការ ដែលសព្វថ្ងៃកំពុងតែរង់ចាំស្តាប់លទ្ធផលចុងក្រោយនៃបណ្តឹងនៅឡើយ ។

ក្រោយពីមានការឃ្លើសចិត្តជាមួយ និងក្លូបលវីតណេស រដ្ឋាភិបាលបានបង្កើតអង្គការឃ្លាំមើលព្រៃឈើ ដើម្បីផ្សព្វផ្សាយនូវរបាយការណ៍សំខាន់ៗអំពីការកាប់ឈើខុសច្បាប់ នៅមុនកិច្ចប្រជុំម្ចាស់ប្រទេសផ្តល់ជំនួយអន្តរជាតិ នៅឆ្នាំ ២០០១ ក្នុងដំណាក់ការនោះ នាយករដ្ឋមន្រ្តីបានគំរាមកំហែងប្តឹងនាយកក្លូបលវីតណេសពីបទញុះញង់ អោយមានការប្រព្រឹត្តបទល្មើស បទផ្សព្វផ្សាយពត៌មានមិនពិត និងបទបរិហាកេរ្តិ៍ ។

ទង្វើនេះ ជាការតបទៅនឹងការទាមទាររបស់បណ្តាញសហគមន៍ព្រៃឈើ កាលពីថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០២ ។ ការចោទប្រកាន់ទាំងនេះមិនសមហេតុផល ហើយបណ្តឹងរបស់រដ្ឋាភិបាលដែលបានប្តឹងទៅតុលាការនោះក៏បានបញ្ឈប់វិញ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ីបានរាយការណ៍ថា "***រដ្ឋាភិបាលកម្ពុជាកំពុងប៉ុនប៉ងបំភិតបំភ័យ និងបិទមាត់ក្រុមមួយដែលការត្រួតពិនិត្យការកាប់ព្រៃឈើខុសច្បាប់របស់ពួកគេ ត្រូវបានទទួលស្គាល់ជាអន្តរជាតិ***"[១៣] ។

អ្នកដឹកនាំសិទ្ធិមនុស្សនៅកម្ពុជានាពេលថ្មីៗនេះ បានសំដែងនូវការព្រួយបារម្ភដ៏ខ្លាំងមួយចំពោះការកើនឡើងនូវការចាត់វិធានការណ៍ច្បាប់ដែលមិនសមហេតុផល និងមិនស្របតាមនិតិវិធីមកធ្វើជាមធ្យោបាយមួយដើម្បីបំភិតបំភ័យអ្នកការពារសិទ្ធិមនុស្ស និងដើម្បីបន្ទុចបង្អាក់សកម្មភាពការងាររបស់ពួកគេ ។ ទង្វើបែបនេះជាសញ្ញានៃការផ្លាស់ប្តូរទំរង់ក្នុងការអនុវត្តន៍ការបំភិតបំភ័យ ការគំរាមកំហែងលើរូបរាងកាយមកជាការគំរាមកំហែងតាមផ្លូវច្បាប់វិញ ដែលមើលទៅហាក់ដូចជា មានលក្ខណៈស្របតាមផ្លូវច្បាប់ជាងមុន ហើយបញ្ហានេះតំរូវអោយមានការឆ្លើយតបព្រមគ្នា និងដោយប្រុងប្រយ័ត្នពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលរួមទាំងបណ្តាញគាំទ្រការងាររបស់អង្គការទាំងនោះផង ។

## អង្គការមិនមែនរដ្ឋាភិបាលដែលមានចរិតបំរើនយោបាយ

សកម្មភាពជាបន្តបន្ទាប់របស់អង្គការគាំទ្ររដ្ឋាភិបាលដែលច្រើនតែមានសកម្មភាពហិង្សា និងខុសច្បាប់ជាការបារម្ភឥតឈប់ឈរមួយចំពោះសង្គមស៊ីវិល ។ ជាធម្មតាទោះបីពុំមែនជាការគំរាមកំហែងផ្ទាល់មកលើអ្នកការពារសិទ្ធិមនុស្ស ឬអង្គការសិទ្ធិមនុស្សក្តីក៏ក្រុមនេះបានផ្តល់លទ្ធភាពអោយរដ្ឋាភិបាលកម្ពុជាបំភ័នដល់មតិសាធារណៈទូទៅ រដ្ឋាភិបាលបរទេស និងដែលជាច្រកអន្តរជាតិមួយដែលធ្វើអោយគេជឿថារដ្ឋាភិបាលកំពុងតែស្វះស្វែងក្នុងការបញ្ចប់នូវបញ្ហាសិទ្ធិមនុស្ស ដោយជុំរុញអោយមានអង្គការគាំទ្ររដ្ឋាភិបាលទាំងនេះ ដែលមានចំនួនយ៉ាងច្រើន ។ បញ្ហានេះអាចបណ្តាលអោយរដ្ឋាភិបាលលែងយកចិត្តទុកដាក់អំពីតំរូវការពិតប្រាកដនៃអង្គការសិទ្ធិមនុស្ស នឹងអាច

---

[១៣] របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស "កម្ពុជា" ការប្រើកងកម្លាំងច្រើនហួសហេតុប្រឆាំងនឹងក្រុមការងារការពារព្រៃឈើសហគមន៍ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០២ ។

បង្ហៃការពិត ឬរារាំងដល់អង្គការទាំងនោះទៅវិញនៅពេលដែលពួកគេគាំទ្រកម្មវិធីសិទ្ធិមនុស្សយ៉ាងសកម្មមួយ ។ លើសពីនេះទៅទៀតក្រុមគាំទ្ររដ្ឋាភិបាល ដូចជា **ក្រុមក្មេងវត្ត** ដែលចុះបញ្ជីជាអង្គការមិនមែនរដ្ឋាភិបាលមួយ ហើយដែលគេដឹងជាទូទៅថាបានទទួលថវិកាគាំទ្រពីនាយករដ្ឋមន្ត្រី ក្រុមនេះបានធ្វើការវាយប្រហារទៅលើនិស្សិត បណ្ដាលអោយមានរបួសស្នាម ការវាយប្រហារទៅលើតំណាងគណបក្សនយោបាយ និងសហជីពកម្មករដែលធ្វើបាតុកម្ម ដោយសន្ដិវិធីដើម្បីទាមទារផ្នែកច្បាប់ ឬផ្នែកនយោបាយ ។

## ការតាមឃ្លាំមើល

អង្គការក្រៅរដ្ឋាភិបាលភាគច្រើនមានការសង្ស័យថា មានការលួចឃ្លាំមើលពីសំណាក់អាជ្ញាធរប៉ូលីសមូលដ្ឋាន ។ វិធានការណ៍ទប់ស្កាត់តែងតែធ្វើជាប្រចាំ ដូចជា ការជៀសវាងមិនបញ្ជូនបន្តនូវពត៌មានសំខាន់ៗ រួមទាំងពត៌មានតាមទូរស័ព្ទ និងអ៊ីមែលជាដើម ។ នៅភ្នំពេញ បុគ្គលិកសិទ្ធិមនុស្សដែលស៊ើបអង្កេតករណីត្រូវបានជនមិនស្គាល់មុខស្លៀកពាក់ជាជនស៊ីវិលតាមដាន ហើយបញ្ហានេះក៏បានកើតឡើងដល់អង្គការនៅតាមបណ្ដាខេត្តផងដែរ ។ នៅឆ្នាំ១៩៩៧ គណបក្សប្រជាជនកម្ពុជាដែលកាន់អំណាចបានបង្កើត គណៈកម្មការត្រួតពិនិត្យអង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមានគោលដៅដើម្បីស៊ើបអង្កេតលើអង្គការណាដែលគេបានកំណត់មួយចំនួន ជាពិសេសអង្គការដែលពាក់ព័ន្ធទៅនឹងការងារសិទ្ធិមនុស្ស ។

## ផលប៉ះពាល់ដោយការគំរាមកំហែងទៅលើការងារសិទ្ធិមនុស្សនៅកម្ពុជា

## បុគ្គលិកសិទ្ធិមនុស្ស

ការគំរាមប្រើហិង្សាមកលើ និងអំពើហិង្សាជាក់ស្តែង ព្រមទាំងរូបភាពបំភិតបំភ័យមួយចំនួនទៀត ដែលបានពិភាក្សាមកខាងលើបានបង្ករការលំបាក ការរារាំង និងបំបាក់ទឹកចិត្តដល់បុគ្គលិកសិទ្ធិមនុស្សមិនអោយអនុវត្តនូការងាររបស់គេឱយអស់ពីសមត្ថភាពបាន ។ ការចោទប្រកាន់ដោយមិនសមហេតុផល និងការចាត់វិធានការណ៍ច្បាប់ដោយបំពានបានធ្វើអោយមានកង្វល់យ៉ាងខ្លាំង ពីព្រោះគេគ្មានពេលពន្យា ឬមធ្យោបាយតាមច្បាប់ណាមួយដើម្បីជួយដល់ជនរងគ្រោះក្នុងខណៈពេលដែលពួកគេរង់ចាំលទ្ធផលចុងក្រោយនៃដំណើរការក្ដីពីតុលាការឡើយ ។ នៅពេលពួកគេមានរឿងកើតឡើង គេអាចត្រូវចាប់អូសខ្លួនយកទៅភ្លាមយ៉ាងពិតប្រាកដ ។

ផលវិបាកអ្នកការពារសិទ្ធិមនុស្សអាចមានការរុញរាក្នុងការចុះទៅធ្វើការតាមតំបន់មួយចំនួន ដូចជា ការស្ទាក់ស្ទើរក្នុងការបន្តស៊ើបអង្កេតករណីមួយចំនួន ឬមានការធ្លាក់ទឹកចិត្តក្នុងការបន្តការងារស៊ើបអង្កេតខ្លះៗ ។ ឧទាហរណ៍ ជាលទ្ធផលដោយការគំរាមកំហែង និងការប្រើអំពើហិង្សា ការិយាល័យឧត្តមស្នងការជាន់ខ្ពស់ជនភៀសខ្លួនបានបញ្ឈប់សកម្មភាពប្រតិបត្តិការការងាររបស់ខ្លួននៅខេត្តមណ្ឌលគីរី និងរតនៈគីរី[១៤] ។ នាពេល

[១៤] ឯកសារសង្ខេបរបស់លីកាដូ -ការគំរាមកំហែងមកលើអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០០២ ។

បច្ចុប្បន្ន ការិយាល័យនេះមានលទ្ធភាពទទួលជួបជនជាតិម៉ុងតាណាត ដែលស្វែងរកសិទ្ធិជ្រកកោនបានធ្វើដំណើរមកដល់ការិយាល័យឧត្តមស្នងការជាន់ខ្ពស់ជនភៀសខ្លួននៅភ្នំពេញដោយសុវត្ថិភាពប៉ុណ្ណោះ ។ អង្គការអាដហុកគឺជាអង្គការសិទ្ធិមនុស្សតែមួយគត់ ដែលកំពុងប្រតិបត្តិការការងារនៅខេត្តរតនៈគីរី ហើយការិយាល័យពួកគេនៅទីនោះបានប្រឈមមុខទៅនឹងហេតុការណ៍ទង្គុកទង្គើពីសំណាក់មន្ត្រីរដ្ឋាភិបាល នៅពេលណាដែលបុគ្គលិកអង្គការសិទ្ធិមនុស្សព្យាយាមជួយដល់ក្រុមជនជាតិម៉ុងតាណាត ដែលស្វែងរកសិទ្ធិជ្រកកោនជាជនភៀសខ្លួននោះ ។

ស្ថិតនៅក្នុងកិរិតស្ថានភាពដ៏ខ្ពស់មួយនៃការគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្ស ដែលប្រព្រឹត្តិដោយអាជ្ញាធររដ្ឋាភិបាលនឹងបង្ករអោយមានភាពមិនទុកចិត្តគ្នារវាងបុគ្គលិកសិទ្ធិមនុស្ស និងមន្ត្រីរដ្ឋាភិបាលព្រមទាំងធ្វើអោយមានការថយចុះនូវសក្តានុពលភាពសំរាប់ពួកគេក្នុងការធ្វើការរួមគ្នា ដើម្បីអោយសំរេចបាននូវគោលដៅរួមមួយផងដែរ ប្រសិនបើមានការអត់ឱនសណ្តោសប្រណីនោះ ។ ប៉ុន្តែក៏នៅមានលទ្ធភាព ដើម្បីកែលំអដែរ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមានមោទនៈភាពខ្ពស់ចំពោះការទំនាក់ទំនងសហប្រតិបត្តិការ ដែលពួកគេបានជួបពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាននានា ជាពិសេសអាជ្ញាធរថ្នាក់ក្រោម ដែលជាផ្នែកមួយនៃការពន្យល់អំពីជោគជ័យ ដែលអង្គការមិនមែនរដ្ឋាភិបាលទទួលបានក្នុងវិស័យមួយចំនួន ដូចជា ការឃ្លាំមើលស្ថានភាពក្នុងពន្ធនាគារ ការបើកវគ្គហ្វឹកហ្វឺន និងសិក្ខាសាលាដល់ប៉ូលីសជាដើម ។ ប៉ុន្តែការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរមកលើអ្នកការពារសិទ្ធិមនុស្សជាការអន្តរាយដល់ទំនាក់ទំនងដ៏ល្អទាំងនេះ។

## សង្គមស៊ីវិល

សង្គមស៊ីវិលក៏ទទួលរងគ្រោះដែរ ។ ជនរងគ្រោះពីសំណាក់ការរំលោភសិទ្ធិមនុស្សមានការរុញរាក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួនដើម្បីយុត្តិធម៌ ដូចជាការធ្វើបណ្តឹងមកអង្គការសិទ្ធិមនុស្ស ការស្វែងរកអន្តរាគមន៍ពីសំណាក់ប៉ូលីស និងតុលាការដើម្បីទប់ទល់នឹងជនល្មើសនៅពេលដែលគេឃើញអ្នកការពារសិទ្ធិមនុស្ស ត្រូវបានគេធ្វើបាបគំរាមកំហែង និងបំភិតបំភ័យជាដើម ។ ការប្រឹងប្រែងផ្ទាល់ខ្លួនដើម្បីស្វែងរកយុត្តិធម៌ហាក់ដូចជាគ្មានប្រយោជន៍ហើយជួបតែគ្រោះថ្នាក់ សូម្បីតែបុគ្គលិកទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិក៏ត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ព្រមទាំងការរំលោភបែបនេះទៅហើយ ។ សមាជិកសហគមន៍ក៏មានការរុញរាក្នុងការដែលខ្លួនត្រូវបានគេឃើញថាបានធ្វើការជាមួយអង្គការសិទ្ធិមនុស្ស ។ អំពើពុករលួយដ៏ល្បីល្បាញ និងកង្វះយុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការកាន់តែធ្វើអោយមានការភ័យខ្លាចខ្លាំងឡើងថែមទៀត ។ ការបំភិតបំភ័យនេះក៏បានរួមចំណែកក្នុងការបង្ករអោយមានភាពស្ទាក់ស្ទើរជាបន្តរបស់សាធារណៈជនទូទៅក្នុងការចូលរួម សូម្បីតែក្នុងលំដាប់ថ្នាក់ទូទៅនៃឆាកនយោបាយក៏ដោយ ដូចជាការបញ្ចេញទស្សនៈនយោបាយការិះគន់គោលនយោបាយរដ្ឋាភិបាល ឬទង្វើរបស់រដ្ឋាភិបាល និងការចូលរួមក្នុងការជំទាស់នយោបាយដោយសន្តិវិធីក្តី ។

ជាទូទៅការគំរាមកំហែងដល់បុគ្គលិកការពារសិទ្ធិមនុស្សមានការប៉ះពាល់មកលើប្រជាពលរដ្ឋ ដោយបានកំណត់នូវសេរីភាព ហើយទង្វើនេះពិតជាការរំលោភលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការចូលរួមក្នុងសមាគម និងសេរីភាពក្នុងការប្រជុំជាដើម ដែលជាសិទ្ធិក្នុងការចូលរួមដោយសេរី និងគ្មានការភ័យខ្លាចនៅក្នុងដំណើរការនៃលទ្ធិប្រជាធិបតេយ្យ ។

## ការកែលំអយន្តការដើម្បីការពារ

បុគ្គលិកសិទ្ធិមនុស្សគ្រប់រូបត្រូវតែបង្កើនវិធានការសន្តិសុខផ្ទាល់ខ្លួន ។ អង្គការសិទ្ធិមនុស្សនិមួយៗត្រូវកំណត់នូវការទទួលខុសត្រូវរបស់ខ្លួនចំពោះបុគ្គលិកអោយបានច្បាស់ ព្រមទាំងការកែលំអនូវយន្តការទាំងឡាយដើម្បីធានាអោយបាននូវការអនុវត្តន៍សកម្មភាព ។ ត្រូវបង្កើតនូវមូលនិធិសំរាប់ជំនួយបន្ទាន់ក្នុងអង្គការនិមួយៗ ឬបង្កើតមូលនិធិសង្គ្រោះរួមមួយក្នុងចំណោមអង្គការទាំងឡាយអាចជាយន្តការការពារមួយយ៉ាងប្រសើរ ។ មូលនិធិជំនួយសង្គ្រោះបែបនេះអាចជួយអោយបុគ្គលិក ដែលប្រឈមនឹងគ្រោះថ្នាក់លាក់ខ្លួនបានជាបន្ទាន់ ។ ជាការពិតលីកាដូ និងអង្គការផ្សេងៗទៀតចាត់ទុកថានេះគឺជាមធ្យោបាយចុងក្រោយបង្អស់មួយ ពីព្រោះជាមួយនឹងថវិកាសំរាប់ចំណាយទៅលើបញ្ហាជាការផ្តល់នូវដំណឹងដ៏ច្បាស់មួយដល់ជនរងគ្រោះ ថាគេអាចជួបគ្រោះថ្នាក់ខ្ពស់តែនៅពេលណាដែលគេស្វែងរកយុត្តិធម៌និងទាមទារសិទ្ធិសំរាប់ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ លើសពីនេះទៀត ការធ្វើបែបនេះក៏ជាសញ្ញាមួយប្រាប់ដល់ជនល្មើសថាយុទ្ធសាស្ត្របំភិតបំភ័យរបស់ពួកគេកន្លងមកទទួលបានជោគជ័យមែន ។

ស្របជៀងគ្នានេះ យន្តការការពារពីខាងក្រៅដ៏មានប្រសិទ្ធិភាពក៏ត្រូវស្ថាបនាឡើងផងដែរ ។ លើសពីនេះទៀត លីកាដូសូមស្នើអោយមានការបង្កើននូវកិច្ចសំរបសំរួល និងការដោះស្រាយយ៉ាងសកម្មចំពោះវិបត្តិទាំងឡាយពេលកើតមាន ព្រមទាំងពិចារណាក្នុងការបង្កើត "**បណ្តាញប្រព្រឹត្តិកម្មបន្ទាន់**" ថ្នាក់តំបន់គឺជាចំណុចអាទិភាពបន្ទាន់មួយ ។

ប៉ុន្តែការគំរាមកំហែងភាគច្រើនចេញពីប្រភពមន្ត្រីរដ្ឋាភិបាល ដូច្នេះការស្នើអោយរដ្ឋាភិបាលជួយការពារថ្នាក់ជាតិនោះគឺជាការមិនអាចអនុវត្តន៍ទៅបានឡើយ ។ អ្នកការពារសិទ្ធិមនុស្សម្នាក់ដែលមិនបញ្ចេញឈ្មោះបាននិយាយថា ***"នៅកម្ពុជា អ្នកត្រូវការពារខ្លួនដោយខ្លួនឯងពីព្រោះប៉ូលីសមិនការពារអ្នកទេ ប៉ុន្តែប៉ូលីសនេះ ហើយជាមនុស្សដែលអ្នកត្រូវតែខ្លាចច្រើនជាងគេ" ។***

ចំពោះហេតុផលនេះ លីកាដូសូមទាមទារយ៉ាងទទូចដល់បណ្តាញអង្គការមិនមែនរដ្ឋាភិបាល ក៏រិតអន្តរជាតិនិងក៏រិតតំបន់ចូរបង្កើនការគាំទ្រ សហប្រតិបត្តិការ និងរួមសហការគ្នាដើម្បីទាក់ទាញអោយមានកិច្ចការពារដល់អ្នកការពារសិទ្ធិមនុស្ស ។ តាមការជាក់ស្តែង ការទាក់ទាញនឹងមានប្រសិទ្ធិភាព ប្រសិនបើការរួមគ្នាត្រូវបានបង្ហាញអោយឃើញឡើង ។ លីកាដូ សូមអបអរសាទរដល់ការប្តេជ្ញាបន្តការត្រួតពិនិត្យលើការគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្សរបស់ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ។ ដើម្បីអោយសំរេចបាន

និងការផ្លាស់ប្តូរជានិរន្តរ៍នៃគោលការណ៍ សកម្មភាពទាំងឡាយត្រូវអនុវត្តន៏រួមមានរាល់ការរំលោភបំពានសិទ្ធិមនុស្ស ត្រូវកសាងសំណុំឯកសារនឹងផ្សព្វផ្សាយជាសាធារណៈដល់មជ្ឈដ្ឋានក៏រិតជាតិ និងសហគមន៍អន្តរជាតិ ដូចជា រដ្ឋាភិបាលបរទេស ម្ចាស់ជំនួយ អង្គការសិទ្ធិមនុស្សនានា និងពលរដ្ឋទូទៅក្នុងពិភពលោក ។

## អនុសាសន៍

លីកាដូ នៅតែមានការបារម្ភយ៉ាងខ្លាំងចំពោះការគំរាមកំហែង ការបំភិតបំភ័យ និងហិង្សាលើអ្នកការពារសិទ្ធិមនុស្សទាំងឡាយ ។ ដោយគិតដល់ភាពធ្ងន់ធ្ងរនៃស្ថានភាពរំលោភសិទ្ធិទាំងនេះ លីកាដូសូមអំពាវនាវអោយមានវិធានការដូចខាងក្រោមៈ

## *រាជរដ្ឋាភិបាលកម្ពុជា*

- រដ្ឋាភិបាលត្រូវតែទទួលស្គាល់សារសំខាន់នៃអង្គការក្រៅរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍សង្គមស៊ីវិលកម្ពុជា ព្រមទាំងទទួល និងសន្យាអនុវត្តន៍អោយបានត្រឹមត្រូវចំពោះអង្គការសិទ្ធិមនុស្ស ។ តំរិយាបទរារាំងដូចបច្ចុប្បន្នជាមួយនឹងការសន្យាតែមាត់ចំពោះសិទ្ធិមនុស្សជាទង្វើមិនអាចទទួលយកបានឡើយ ។ ការសន្យានេះនឹងមានទំនាក់ទំនងយ៉ាងសកម្មក្នុងការលុបបំបាត់ចោលនូវឧបសគ្គទាំងឡាយដែលរារាំងដល់ការប្រតិបត្តិការងាររបស់អង្គការសិទ្ធិមនុស្ស ។ ជាពិសេស តម្លាភាពនៅក្នុងការស៊ើបអង្កេតជាកត្តាសំខាន់បំផុត ។
- រាជរដ្ឋាភិបាលកម្ពុជា គួរតែចាត់វិធានការជាជំហ៊ាន១ ដើម្បីផ្តន្ទាទោសដល់ជនល្មើស ដែលប្រព្រឹត្តិអំពើហិង្សា និងបំភិតបំភ័យមកលើអ្នកការពារសិទ្ធិមនុស្សទាំងឡាយ ។
- រដ្ឋាភិបាលត្រូវអនុវត្តតាមច្បាប់ជាតិ និងការសន្យាគោរពច្បាប់អន្តរជាតិរបស់ខ្លួនដែលហាមប្រាមមិនអោយប្រើការបំភិតបំភ័យ និងការបង្ខិតបង្ខំដើម្បីរារាំង ឬបំភិតបំភ័យការងាររបស់អ្នកការពារសិទ្ធិមនុស្សឡើយ[១៥] ។
- លីកាដូ សូមអំពាវនាវយ៉ាងទទូចអោយរាជរដ្ឋាភិបាលគាំទ្រសេចក្តីប្រកាសនៃមហាសន្និបាត អង្គការសហប្រជាជាតិឆ្នាំ ១៩៩៩ ស្តីអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការបំរើសង្គមដើម្បីលើកកំពស់នឹងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល[១៦] ។ ជាពិសេសរាជរដ្ឋាភិបាលគួរតែប្រកាន់ខ្ជាប់តាមស្មារតីនៃមាត្រា ៩ និងមាត្រា ១២ នៃសេចក្តីប្រកាសនេះដែលចែងអំពីសិទ្ធិបុគ្គល និងសិទ្ធិរបស់អង្គការ/សមាគមក្នុងការទាមទារនឹងរិះគន់ដល់សកម្មភាព

[១៥] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តកត្តិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ។ មាត្រា ១៩ ២១ និង ២២ នៃកត្តិការសញ្ញានេះចែងអំពីសេរីភាពក្នុងការបញ្ចេញមតិ ប្រជុំ និងសិទ្ធិចូលជា សមាគម ។

[១៦] អង្គការសហប្រជាជាតិ ឯកសារយោង A/RES/53/144 ថ្ងៃទី ៨ ខែមិនា ឆ្នាំ ១៩៩៩ ។ សូមមើលឧបសម្ព័ន្ធ ៣ ។

រដ្ឋាភិបាល ហើយតំរូវអោយរដ្ឋផ្តល់កិច្ចការពារដល់បុគ្គលក៏ដូចជាអង្គការ/សមាគមពីការគំរាមកំហែងទាំងពួង ។

## *រដ្ឋាភិបាលបរទេស និងទីភ្នាក់ងារផ្តល់ជំនួយ*

- បង្កើនកិច្ចសហការរវាងរដ្ឋាភិបាល ស្ថានទូតបរទេស និងអង្គការផ្តល់មូលនិធិទាំងឡាយក្នុងការបង្កើតយន្តការការពារអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា គឺជាកិច្ចការសំខាន់ ហើយត្រូវបង្ហាញនូវតំលៃដែលសហគមអន្តរជាតិបានលើកតំកើងអំពីសិទ្ធិមនុស្ស ។
- ក្នុងករណីដែលមានការចាត់វិធានការណ៍ច្បាប់មិនសមស្របដែលធ្វើឡើង ដើម្បីបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស រដ្ឋាភិបាលបរទេសនិងអង្គការផ្តល់មូលនិធិទាំងឡាយគួរតែប្រាប់រាជរដ្ឋាភិបាលកម្ពុជាថា ពួកគេបានដឹងអំពីការចាត់វិធានការណ៍ច្បាប់មិនសមស្របដែលកំពុងប្រើ ដើម្បីគំរាមបុគ្គលិកសិទ្ធិមនុស្ស ។ វិធានការណ៍គាំទ្រអាចរួមមានការបញ្ចុះបញ្ចូល និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាលអោយលុបបំបាត់ចោលនូវឧបសគ្គច្បាប់ដែលរារាំងដល់ការងារសិទ្ធិមនុស្ស ឬផ្តល់ជំនួយផ្នែកច្បាប់ដល់អ្នកការពារសិទ្ធិមនុស្សនៅពេលមានបញ្ហា ។

## *អង្គការសិទ្ធិមនុស្សក៏រិតជាតិ និងអន្តរជាតិនានា*

- អង្គការសិទ្ធិមនុស្សកម្ពុជា និងអង្គការសិទ្ធិមនុស្សអន្តរជាតិនានាគួរតែពិភាក្សាគ្នា និងបង្កើតយន្តការការពារសំរាប់រយៈពេលខ្លី និងយូរអង្វែង ប៉ុន្តែមិនកំណត់រួមមានការតស៊ូមិត និងការការពារផ្លូវច្បាប់ ការបង្កើតមូលនិធិសង្គ្រោះបន្ទាន់សំរាប់បុគ្គលិកអង្គការណាដែលត្រូវ គំរាមកំហែងការបង្កើតនិតិវិធីបណ្តោះចេញជាបន្ទាន់ និងការចូលរួមក្នុងតំបន់ **"បណ្តាញឆ្លើយតបគ្រាមានអាសន្ន"** ។
- ការបង្កើត **"បណ្តាញឆ្លើយតបគ្រាមានអាសន្ន"** ថ្នាក់តំបន់ត្រូវបានចាត់ទុកជាអាទិភាព ។ បណ្តាញបែបនេះអាចចាត់វិធានការផ្សព្វផ្សាយភ្លាម១នូវអំពើគំរាមកំហែងទាក់ទាញអោយអាជ្ញាធរកម្ពុជាចាត់ការជនល្មើសអោយបានត្រឹមត្រូវ និងផ្តល់ផែនការការពារ ព្រមទាំងជំលៀសចេញចំពោះអ្នកការពារសិទ្ធិមនុស្សណាដែលមានបញ្ហា ប្រសិនបើត្រូវការចាំបាច់ ។
- អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាត្រូវចងក្រងជាឯកសារនូវការគំរាមកំហែងទាំងឡាយ រួមទាំងការគំរាមកំហែងមកលើផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់ខ្លួន ហើយធ្វើការផ្សព្វផ្សាយអំពើគំរាមកំហែងនេះ ដើម្បីអោយមានកិច្ចការពារបន្ថែមទៀតដល់អ្នកការពារសិទ្ធិមនុស្ស និងសង្គមស៊ីវិលនៅកម្ពុជាជាទូទៅ ។
- អង្គការសិទ្ធិមនុស្សកម្ពុជា និងអង្គការសិទ្ធិមនុស្សអន្តរជាតិគួរសហការដើម្បីទាក់ទាញអោយរដ្ឋាភិបាលសន្យាអនុវត្តន៍តាមសេចក្តីប្រកាសជាសកលនៃមហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ១៩៩៩ ស្តីអំពី

សិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ដើម្បីលើកកំពស់ និងការពារសិទ្ធិសេរីភាព ជាមូលដ្ឋានដែលទទួលត្រូវបានស្គាល់ជាសកល ។

- អង្គការសិទ្ធិមនុស្សកម្ពុជា និងអង្គការសិទ្ធិមនុស្សអន្តរជាតិទាំងឡាយគួរឃ្លាំមើលយ៉ាងប្រុងប្រយ័ត្នចំពោះការបន្តបង្កើតអង្គការដែលមានចរិតនយោបាយគាំទ្ររដ្ឋាភិបាល និងត្រូវប្រាជកថា រាជរដ្ឋាភិបាលបានដឹងថា សហគមន៍អន្តរជាតិកំពុងតែសង្កេតមើលយ៉ាងយកចិត្តទុកដាក់នឹងមិនអាចត្រូវបានបោកបញ្ឆោតដោយល្បិចកលទាំងនេះទេ ។

## របាយការណ៍ការវាយប្រហារមកលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ចាប់ពីឆ្នាំ ១៩៩៧ -២០០៣[១៧]

| ឆ្នាំ ខែ | ព្រឹត្តិការណ៍ |
|---|---|
| ១៩៩៧ សីហា: | អ្នកស៊ើបអង្កេតនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (UNCOHCHR) ទទួលរងការបំភិតបំភ័យដោយមានការបាញ់កាំភ្លើង អាកា ៤៧ ពីលើក្បាល ក្នុងខណៈដែលពួកគេកំពុងស៊ើបអង្កេតនៅរណ្តៅសាកសពមួយ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សនៅអាស៊ីក៏បានរាយការណ៍ផងដែរថា ក្រោយមកអ្នកស៊ើបអង្កេតទាំងនោះក៏បានឮតាមវិទ្យុទាក់ទងនូវសំលេងមន្រ្តីយោធារដ្ឋាភិបាលសំរេចថាតើត្រូវសំលាប់អ្នកទាំងនោះដែរ ឬទេ ។ |
| ១៩៩៧ តុលា: | គណបក្សប្រជាជនដែលកាន់អំណាចបានបង្កើតគណៈកម្មការដើម្បីត្រួតពិនិត្យអង្គការមិនមែនរដ្ឋាភិបាល ដែលមានគោលដៅធ្វើការស៊ើបអង្កេតទៅលើអង្គការដែលបានកំណត់ទុកមួយចំនួនជាពិសេសអង្គការដែលមានគោលការណ៍លើការងារសិទ្ធិមនុស្ស ។ |
| ១៩៩៨ កុម្ភៈ: | យោធាបានប្តឹងអង្គការ CHRAC ទៅតុលាការពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតរបស់អង្គការទៅលើករណីគំរាមកំហែងមកលើបុគ្គលិកសិទ្ធិមនុស្សម្នាក់នៅខេត្តកំពង់ចាម ។ អង្គភាពយោធាមួយបានដាក់ពាក្យបណ្តឹងទៅតុលាការកំពូល និងរដ្ឋសភាដោយទាមទារអោយសងជំងឺចិត្តចំនួន ៧០.០០០ ដុល្លាអាមេរិក ដោយចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ។ |
| ១៩៩៨ មេសា: | បុគ្គលិកឧត្តមស្នងការអង្គការហសប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានរងរបួសដោយករណីបង្ករបួសស្នាមប្រព្រឹត្តិដោយកងកំលាំងសន្តិសុខរដ្ឋាភិបាលក្នុងខណៈដែលបុគ្គលិករូបនោះកំពុងត្រួតពិនិត្យបាតុកម្ម ។ បុគ្គលិករូបនោះត្រូវសំរាកព្យាបាលនៅមន្ទីរពេទ្យ ។ |

[១៧] ពតិមានទទួលបានពី: របាយការណ៍ទូទៅរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ី ១៩៩៧-២០០២- របាយការណ៍ប្រចាំឆ្នាំរបស់ ADHOC ឆ្នាំ ២០០១ និងរបាយការណ៍នានារបស់លីកាដូ ។ គួរកត់សំគាល់ថា ឧប្បត្តិហេតុដែលបង្ហាញក្នុងតារាងនេះមិនមែនបញ្ចោក់គ្រប់របាយការណ៍នៃរឿងរ៉ាវសំខាន់ៗទាំងអស់នោះទេ- ព្រោះហេតុផលសុវត្ថិភាពបុគ្គលិកបំរើការងារសិទ្ធិមនុស្ស ។

**១៩៩៨ ធ្នូ:** បុគ្គលិកលីកាដូពីរនាក់ ត្រូវបានចាប់ខ្លួន ដោយបទចោទប្រកាន់ និងឃុំខ្លួនក្នុងពន្ធនាគារអស់រយៈពេលមួយខែក្រោយពីគេទាំងពីរបានធ្វើការត្រួតពិនិត្យបាតុកម្មប្រឆាំងនឹងការចាក់កាកសំណល់ដែលមានជាតិពុលនៅក្រុងព្រះស៊ីហនុ ។

**១៩៩៨ ធ្នូ:** សកម្មជនសិទ្ធិមនុស្សរបស់អង្គការអាដហុកម្នាក់ ឈ្មោះ ពួង តុង ត្រូវបានគេសំលាប់នៅខេត្តកណ្តាល ឃាដកម្មនោះទំនងជាពាក់ព័ន្ធទៅនឹងករណីទំនាស់ដីធ្លីយ៉ាងយូរអង្វែងមួយ ដែលជនរងគ្រោះ និងប្រជាជនចំនួន ១៤ គ្រួសារទៀតជាកម្មករការដ្ឋានកិនថ្មបានមានទំនាស់ជាមួយក្រុមហ៊ុន ។ ជនរងគ្រោះគឺជាតំណាងប្រជាជនទាំង ១៤គ្រួសារនៅក្នុងរឿងជំលោះដីធ្លីនោះក្នុងការប្តឹងផ្តល់មកតុលាការ ។

**១៩៩៨ ធ្នូ:** បុគ្គលិកឧត្តមស្នងការអង្គការសហប្រជាជាតិម្នាក់បានទទួលរងការវាយប្រហារដោយកងរាជអាវុធហត្ថចំនួន៤នាក់ក្នុងខណៈដែលបុគ្គលិករូបនោះកំពុងជិះម៉ូតូនៅក្នុងទីក្រុងភ្នំពេញ ។ កងរាជអាវុធហត្ថបានគំរាមសំលាប់ជនរងគ្រោះ ហើយក្រោយមកក៏បានដាល់មុខគាត់លួចម៉ូតូរបស់គាត់ចាប់គាត់ដាក់ក្នុងរថយន្តរបស់ពួកគេ ហើយបើកយកទៅឆ្ងាយ ។ នៅក្នុងរថយន្តនោះកងរាជអាវុធហត្ថបានដកហូតយកកាបូប ទូរស័ព្ទ វិទ្យុទាក់ទង និងថវិកា ព្រមទាំងសំភារៈផ្ទាល់ខ្លួនផ្សេងៗទៀត ។ បុគ្គលិករូបនោះក៏បានលោតចេញពីរថយន្ត ហើយរត់សំដៅទៅរកសន្តិសុខសណ្ឋាគារនៅតាមផ្លូវធំមួយក្នុងទីក្រុង ។ ក្រោយមកបុគ្គលិករូបនោះក៏បានទទួលសំភារៈរបស់គាត់ទាំងអស់ត្រឡប់មកវិញ ក្រោយពីមានការចរចាររវាងឧត្តមស្នងការអង្គការសហប្រជាជាតិ និងកងរាជអាវុធហត្ថ ។

**១៩៩៩ មករា:** តំណាងអង្គការសិទ្ធិមនុស្សកម្ពុជានៅក្នុងខេត្តចំនួន ៧ ត្រូវបានបំភិតបំភ័យដោយអាជ្ញាធររដ្ឋាភិបាល ហើយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់ត្រូវបានគំរាមចាប់ក្នុងយុទ្ធនាការប្រមូលហត្ថលេខាពីប្រជាជនកម្ពុជា ដើម្បីស្នើសុំអោយអង្គការសហប្រជាជាតិបង្កើតនូវសាលាជំរះក្តីអន្តរជាតិដើម្បីកាត់ទោសខ្មែរក្រហម ។

**១៩៩៩ កក្កដា:** បុគ្គលិកអង្គការលីកាដូ ២ នាក់បានឡើងតុលាការ ក្រោយពីត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៩៨ ក្រោយពេលដែលគេទាំងពីរនាក់បានត្រួតពិនិត្យបាតុកម្មនៅទីក្រុងព្រះសីហនុ។ ទោះបីជាបុគ្គលិកទាំងពីរនាក់នោះត្រូវបានលើកលែងការចោទប្រកាន់ក៏ដោយ ក៏ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា និងអ្នកសង្កេតការអន្តរជាតិបានលើកឡើងថា គេមិនគួរនឹងបើកសវនាការទាល់តែសោះ ពីព្រោះពុំមានភស្តុងតាងគ្រប់គ្រាន់ និងកំហុសឆ្គងខាងនីតិវិធី ។

**១៩៩៩ កញ្ញា:** យោធាកងពលលេខ ២ បានផ្ញើលិខិតគំរាមជាផ្លូវការមកការិយាល័យឧត្តមស្នងការអង្គការសហ

| | |
|---|---|
| | ប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាខេត្តកំពង់ចាមព្រមទាំងអង្គការសិទ្ធិមនុស្សនានានៅកំពង់ចាម ដោយចោទប្រកាន់មកលើបុគ្គលិកអង្គការសិទ្ធិមនុស្សថាបានញុះញង់អោយប្រជារាស្ត្រធ្វើពាក្យប្តឹងអង្គភាពយោធាចំពោះការដោះស្រាយបញ្ហាជំលោះដីធ្លីរបស់ពួកគេ ។ ប៉ុន្តែពួកគេបានគំរាមទាមទារជំងឺចិត្តចំពោះការបរិហាកេរ្តិ៍ ប្រសិនបើការញុះញង់នោះឈប់ ពួកគេក៏នឹងមិនបន្តបញ្ហានេះតទៅទៀតដែរ ។ |
| **២000 មិនា:** | នៅខេត្តកោះកុង បុគ្គលិកអាដហុកត្រូវបានគេគំរាមចាប់ខ្លួនក្រោយពីបានធ្វើអន្តរាគមន៏ក្នុងករណីជួញដូរមួយ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ីបានរាយការណ៏ថា "ស្ត្រីម្នាក់ ដែលលក់កូនរបស់ខ្លួនបានចោទប្រកាន់អ្នកសម្របសម្រួលអាដហុកប្រចាំខេត្តពីបទបង្ករបួសស្នាម ។ ក្រោយមកស្ត្រីរូបនោះបានដកពាក្យបណ្តឹងរបស់ខ្លួនហើយបានសារភាពថា ខ្លួនធ្វើបែបនេះដោយសារមានការគាបសង្កត់ពីសំណាក់នគរបាលអោយនាងធ្វើបណ្តឹង[១៨] ។ |
| **២000 កញ្ញា:** | អភិបាលស្រុកនៅខេត្តកំពតបានបញ្ជាអោយបិទការហ្វឹកហ្វឺនអ្នកបោះឆ្នោតដែលហ្វឹកហ្វឺន ដោយ COMFREL ជាអង្គការត្រួតពិនិត្យការបោះឆ្នោត ។ អភិបាលស្រុកបានលើកឡើងថា អង្គការនោះពុំមានការអនុញ្ញាតជាលាយល័ក្ខអក្សរដើម្បីបើកវគ្គមកធ្វើជាមូលហេតុនៃការបិទវគ្គហ្វឹកហ្វឺននោះ ។ |
| **២000 តុលា:** | បុគ្គលិកឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ត្រូវបានគំរាមកំហែងភ្ជង់នឹងកាំភ្លើងដោយទាហាន ក្រោយពីបានធ្វើអន្តរាគមន៏ក្នុងករណីទាហ៊ានបានគំរាមកំហែងបាញ់សមាជិកសភាគណបក្សសមរង្ស៊ី ។ |
| **២000 ធ្នូ:** | នាយករដ្ឋមន្ត្រីបានចោទប្រកាន់ថាអង្គការសិទ្ធិមនុស្សបានជុំរុញអោយមានអំពើភេរវកម្ម ដោយចោទថាបានផ្តល់ជំរក និងជួយឧបត្ថមដល់ក្រុមភេរវករ ក្រោយពីមានការវាយប្រហារដោយក្រុមអ្នកច្បាំងដើម្បីសេរីភាពកម្ពុជា (CFF) ក្នុងខែវិច្ឆិកា ឆ្នាំ២000 នៅភ្នំពេញនោះ ។ នាយករដ្ឋមន្ត្រីបានប្រើភាសាគំរាមកំហែងនេះដើម្បីព្រមានបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដើម្បីអោយដឹង ថា "ពួកគេមិនអាចគេចពីការចាប់ចងបានទេ"[១៩] ។ |

---

[១៨] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ឆ្នាំ ២00២ ។ របាយការណ៏ពិភពលោក : ព្រឹត្តិការណ៏ឆ្នាំ ២00១ ទំព័រ ៤ ។

[១៩] Cambodia Daily 2000, (បកប្រែក្រៅផ្លូវការ) " ហ៊ុន សែន ថ្លែងនៅខេត្តពោធិសាត់" ទី ៥ ធ្នូ ។ សូមអាន Cambodia Daily 2000 ផងដែរ " នាយករដ្ឋមន្ត្រីព្រមានថា កុំលាក់ CFF" ដោយ ហម សំណាង ទី៦ ធ្នូ ។ ដំណឹងពេលល្ងាច ឆ្នាំ ២000 សរសេរថា "សម្តេចនាយករដ្ឋមន្ត្រីបានអំពាវនាវដល់អង្គការកុំការពារភេរវជន"-ដំណឹងពេល ល្ងាច Vol 5, # 680 ។ រស្មីកម្ពុជា ឆ្នាំ ២000 សរសេរថា " ហ៊ុន សែន បានព្រមានដល់បុគ្គលិកសិទ្ធិមនុស្ស កុំអោយលាក់ភេរវជន " ថ្ងៃព្រហស្បត៍ទី ៧ធ្នូ ។ សំលេងយុវជន ឆ្នាំ ២000 " ហ៊ុនសែន គំរាមដាក់ខ្នោះបុគ្គលិកសិទ្ធិមនុស្ស និងប្រធានគណបក្សប្រឆាំង" ទី ៦ ធ្នូ ។ Associated Press 2000, " ហ៊ុន សែន ព្រមានក្រុមសិទ្ធិមនុស្សក្នុងខណៈមានការចាប់ចងនៅបន្ត" ទី ៥ ធ្នូ ។

**២០០១ មករា:** នៅពេលដែលអង្គការក្លូបលវីតណេស ដែលជាអង្គការមានគោលការណ៍ឃ្លាំមើលព្រៃឈើជាផ្លូវការបានចេញផ្សាយរបាយការណ៍ស្តីអំពីការកាប់បំផ្លាញព្រៃឈើខុសច្បាប់មុនកិច្ចប្រជុំអ្នកផ្តល់ជំនួយអន្តរជាតិ នាយករដ្ឋមន្ត្រីបានគំរាមបណ្តេញក្រុមនេះអោយចេញពីកម្ពុជា ។ ក្រោយមកដោយមានការគាបសង្កត់ពីសំណាក់ក្រុមអ្នកផ្តល់ជំនួយទើបគាត់មិនបានអនុវត្តន៍តាមការគំរាមកំហែងនោះវិញ ។

**២០០១ មករា:** តុលាការខេត្តកណ្តាលបានកោះអញ្ជើញមន្ត្រីអង្គការក្លូបលវីតណេស ២ នាក់ដោយចោទប្រកាន់ពីបទរំលោភលើសិទ្ធិបុគ្គល ។ ព្រះរាជអាជ្ញាបានប្រាប់ពួកគេទាំងពីរនាក់នោះថា ការត្រួតពិនិត្យរោងចក្រក្តារបន្ទះរបស់មន្ត្រីទាំងពីរនោះ តុលាការថាគេអាចចោទប្រកាន់មន្ត្រីនោះបានតាមមាត្រា៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលទាក់ទងទៅនឹងការរំលោភលើសិទ្ធិបុគ្គល ។ ការចោទប្រកាន់ដោយរំលោភនោះបណ្តាលមកពីការភ្ញាក់ផ្អើលក្នុងការត្រួតពិនិត្យរោងចក្រក្តារបន្ទះ ។ មន្ត្រីអង្គការក្លូបលវីតណេសមិនត្រូវបានអនុញ្ញាតអោយចូលហើយថែមទាំងត្រូវសន្តិសុខឃុំខ្លួនអស់រយះពេល ៦ ម៉ោង ។ ក្រោយមកមន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់បានមកដល់ទើបគេអនុញ្ញាត អោយមន្ត្រីក្លូបលវីតណេសចូលក្នុងរោងចក្រ ហើយពួកគេបានរកឃើញឈើខុសច្បាប់អត់មានបោះត្រាទាំងនៅខាងក្នុង និងខាងក្រៅបរិវេណរោងចក្រ ។

**២០០១ កុម្ភៈ:** នាយករដ្ឋមន្ត្រី ហ៊ុន សែន ចោទប្រកាន់ឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាថាបានគាំទ្រការធ្វើកូដកម្មរបស់គ្រូបង្រៀននៅខេត្តកណ្តាល ហើយបានព្រមាននាយក UNDP ថាបានជាប់ពាក់ព័ន្ធក្នុងរឿងនោះ[២០] ។

**២០០១ ឧសភា:** តុលាការក្រុងភ្នំពេញបានធ្វើការចោទប្រកាន់នាយកស្តីទីលីកាដូ ពីបទឃុំឃាំងមនុស្សខុសច្បាប់ ។ ករណីនោះពាក់ព័ន្ធទៅនឹងការរំដោះកុមារីរងគ្រោះអាយុ៧ឆ្នាំដោយនគរបាល ក្រោយមកនគរបាលបានប្រគល់កុមារីនោះមកលីកាដូដើម្បីថែទាំបណ្តោះអាសន្ន ។ ឪពុក-ម្តាយចិញ្ចឹមរបស់កុមារីនោះបានប្តឹងបកលីកាដូពីបទឃុំឃាំងមនុស្សខុសច្បាប់ ។ ទោះបីជាឪពុកម្តាយចិញ្ចឹមត្រូវបានផ្តន្ទាទោសនឹងកាត់សេចក្តីពីបទរំលោភនិងបង្ករបួសស្នាម ហើយលីកាដូត្រូវបានអនុញ្ញាតអោយគ្រប់គ្រងកុមារីនោះបណ្តោះអាសន្ន និងជាអចិន្ត្រៃយ៍ដោយតុលាការដដែលក្តី ក៏ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញានៅតែមិនលើកលែងការចោទប្រកាន់បទឃុំឃាំងមនុស្សខុសច្បាប់មកលើនាយកស្តីទីលីកាដូ ដែលប្តឹងដោយឪពុក-ម្តាយចិញ្ចឹមរបស់កុមារីនោះដែរ ។ ចៅក្រមស៊ើបអង្កេតក្រោយមកក៏បានលើកលែងការចោទប្រកាន់ ។ ឪពុក-ម្តាយចិញ្ចឹមរបស់កុមារីនោះក៏បានបន្តប្តឹងទៅសាលាឧទ្ធរណ៍ទៀត ដែលសព្វថ្ងៃនេះកំពុងរង់ចាំទទួលលទ្ធផលពីតុលាការនៅឡើយ ។

[២០] ខ្មែរ Vol 8, #1291, 9.2.2001

**២០០១ កញ្ញា:** បុគ្គលិកលីកាដូត្រូវបានជនល្មើសតាមឃ្លាំមើលយ៉ាងហោច ៤ ដង ក្នុងខណៈដែលពួកគេធ្វើការស៊ើបអង្កេតករណីជួញដូរមនុស្សមួយ ។ មានការលបតាមដល់ផ្ទះជនរងគ្រោះ ការិយាល័យលីកាដូ និងតាមដល់ផ្ទះអ្នកស៊ើបអង្កេតរូបនោះផងដែរ ។

**២០០១ ធ្នូ:** មានការឃុំខ្លួន និងការបំភិតបំភ័យដល់បុគ្គលិកសមាគមខ្មែរកម្ពុជាក្រោមដែលប្រព្រឹត្តិដោយអាជ្ញាធរខេត្តកំពង់ធំក្នុងខណៈដែលបុគ្គលិករូបនោះធ្វើការស៊ើបអង្កេតករណីបំផ្លិចបំផ្លាញឧបករណ៍នេសាទក្នុងទ្រង់ទ្រាយធំមួយ ។

**២០០២ មិនា:** នគរបាល និងជនជាតិវៀតណាមបានគំរាមកំហែងដល់បុគ្គលិកអង្គការ UNHCR នៅខេត្តមណ្ឌលមណ្ឌលគីរីនៅពេលដែលបុគ្គលិករូបនោះបានជួយធ្វើអន្តរាគមន៍ក្នុងនាមអ្នកស្វែងរកសិទ្ធិជ្រកកោនផ្នែកនយោបាយ ។ ជនជាតិវៀតណាមតំបន់ភ្នំប្រមាណ ៥០០ នាក់ បានសំដៅទៅរកទីកន្លែងស្នាក់នៅរបស់ពួកអ្នកស្វែងរកសិទ្ធិជ្រកកោនខាងនយោបាយក្នុងជុំរំរបស់អង្គការ UNHCR នៅខេត្តមណ្ឌលគីរី ។ នគរបាលកម្ពុជាបានរុញស្ត្រីម្នាក់អោយធ្លាក់ពីលើផ្លូវក្នុងខណៈ ដែលនាងកំពុងរារាំងនគរបាលពីការវាយប្រហារទៅលើផ្ទះរបស់អ្នកបកប្រែភាសាជនជាតិភាគតិចម្នាក់ ។

**២០០២ មិនា:** អ្នកបើកបរកាណូតម្នាក់ដែលបើកដឹកជនភៀសខ្លួននៅក្នុងការងារក្រៅផ្លូវការដែលទាក់ទងទៅនឹងអង្គការ UNHCR ក្រោយមកត្រូវបានចាប់ខ្លួនក្រោមការចោទប្រកាន់ពីបទជួញដូរមនុស្ស ។ អ្នកបើកបរនោះពុំមែនជាបុគ្គលិកអចិន្ត្រៃយ៍ ហើយក៏ពុំមានកិច្ចសន្យាជាផ្លូវការណាមួយជាមួយនឹង UNHCR ដែរ ប៉ុន្តែត្រូវបានចោទប្រកាន់ក្រោយពីគាត់បានដឹកជញ្ជូនជនភៀសខ្លួនទាំងនោះដែល UNHCR កំពុងតែរៀបចំកន្លែងស្នាក់នៅដល់ពួកគេ ។ ក្រោយពីត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ៤ ខែ តុលាការបានដោះលែងជននោះវិញ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំដដែល។

**២០០២ មិនា :** ថ្ងៃទី ៣១ មិនា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា ក្នុងកំឡុងពេលតែមួយខែទៀតប៉ុណ្ណោះ ជុំរុំជនភៀសខ្លួននៅខេត្តរតនៈគីរី និងមណ្ឌលគីរី ត្រូវតែបិទទ្វារ ហើយអ្នកស្វែងរកសិទ្ធិជ្រកកោនថ្មីត្រូវតែទប់ស្កាត់កុំអោយឆ្លងដែនចូលមកក្នុងប្រទេសកម្ពុជា ។

**២០០២ មេសា:** ជុំរំ UNHCR នៅមណ្ឌលគីរីត្រូវបាននគរបាលកម្ពុជា និងមន្ត្រីវៀតណាមលួចដុតបំផ្លាញ ។ ប្រហែល១ ម៉ោងក្រោយមករថយន្តដឹកជញ្ជូនរបស់រដ្ឋាភិបាលចំនួន ១៨គ្រឿង បានដឹកអ្នកភៀសខ្លួនដែលជាអ្នកភ្នំទាំងនោះចេញពីជុំរំប្រមាណ ៥៥០ នាក់សំដៅមកភ្នំពេញ ។ ជុំរំនោះត្រូវបានគេដុតបំផ្លាញចោលហើយបុគ្គលិក UNHCR ត្រូវជំលៀសចេញ ហើយបរិវេណជុំរំប្រមាណ ៥០% ត្រូវបានដុតបំផ្លាញ ។ ប៉ុន្មានខែក្រោយមកមន្ត្រីក្រសួងការបរទេសកម្ពុជាបានស្នើអោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលជនភៀសខ្លួនបិទជំរំនៅខេត្តមណ្ឌលគីរី ។

**២០០២ មេសា:** មន្ត្រីជាន់ខ្ពស់និងអ្នកត្រួតពិនិត្យនៃអង្គការត្រួតពិនិត្យព្រៃឈើឯករាជ្យគ្លូបូលវីតណេស ត្រូវបានវាយនឹងទាត់ធាក់ដួលទៅដី នៅក្បែរការិយាល័យរបស់នាងហើយក្រោយមកក៏មានអ៊ីមែលផ្ញើមកគំរាមថាអោយ "**ឈប់**" គ្លូបូលវីតណេសបានចាត់ទុកករណីនេះថាជាល្បិចបំភិតបំភ័យពីសំណាក់អ្នកដែលមានផលប្រយោជន៍ក្នុងរឿងព្រៃឈើដែលត្រូវទទួលការគំរាមកំហែងពីសំណាក់ការស៊ើបអង្កេតក្នុងរឿងរបស់គេដែលលាតត្រដាងថាការកាប់ព្រៃឈើទាំងនោះគឺជាទង្វើខុសច្បាប់ ។

**២០០២ ធ្នូ :** ក្រោយពីការប្រើប្រាស់អំពើហិង្សា និងការប្រើប្រាស់កំលាំងហួសហេតុ នៃកងនគរបាល និងកងរាជអាវុធហត្ថដើម្បីបំបែកការអង្គុយតវ៉ាដោយសន្តិវិធី នៅភ្នំពេញរបស់បណ្តាញសហគមន៍ព្រៃឈើ( ជាលទ្ធផល១១នាក់ត្រូវចូលពេទ្យ និងក្រោយមកមានម្នាក់ស្លាប់ដោយមិនដឹងមូលហេតុច្បាស់លាស់) នាយករដ្ឋមន្ត្រី និងមន្ត្រីរដ្ឋាភិបាលផ្សេងៗទៀតបានវាយការណ៍ចោទប្រកាន់គ្លូបូលវីតណេសតាមវិទ្យុ និងទូរទស្សន៍ថា បានញុះញង់អោយមានការតវ៉ាដោយហេតុផលនយោបាយ និងថាបានប្រឌិតនូវរបាយការណ៍ស្តីពីអំពើហិង្សា ។

ប៉ុន្មានសប្តាហ៏ក្រោយមកនាយករដ្ឋមន្ត្រីបានប្តឹងជាផ្លូវការទៅប៉ូលីស និងគំរាមចោទប្រកាន់បទល្មើសព្រហ្មទណ្ឌបីករណីមកលើនាយកកម្មវិធី ពីបទញុះញង់អោយមានការប្រព្រឹត្តិខុសឆ្គង បទផ្សព្វផ្សាយពតិមានមិនពិត និងបទបរិហាកេរ្តិ៍ ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សអាស៊ីវាយការណ៍ថា "រដ្ឋាភិបាលកម្ពុជាប៉ុនប៉ងបំភិតបំភ័យ និងបិទមាត់ក្រុមមួយ ដែលការត្រួតពិនិត្យការកាប់បំផ្លាញព្រៃឈើខុសច្បាប់របស់គេ ត្រូវបានទទួលស្គាល់ជាអន្តរជាតិ " ។ ក្រោយមកបណ្តឹងនោះបានដកមកវិញ ។

**២០០៣ មករា:** ការបំភិតបំភ័យដោយប៉ូលីសមកលើនាយកអង្គការមិនមែនរដ្ឋាភិបាលកើតឡើងអាស្រ័យ ដោយនាយករូបនោះមានការពាក់ព័ន្ធនឹងការតស៊ូមតិសហគមន៍អំពីករណីដីធ្លី ដែលជារឿងទាក់ទងនឹងការអង្គុយតវ៉ានៅថ្ងៃទី ៥ ខែធ្នូ ។ ក្រោយពីការិយាល័យអង្គការត្រូវគេលបចូលលួចសំភារៈ ប៉ូលីសមិនបានយកចិត្តទុកដាក់នឹងករណីនោះទេ ប៉ុន្តែបែជាចំណាយពេលពេញមួយថ្ងៃសួរចំលើយនាយកអង្គការអំពីសកម្មភាពនៅក្នុងអង្គការ និងអំពីសមាជិកគ្រួសាររបស់នាយកទៅវិញ ។

ក្រោយមក នាយកអង្គការនោះក៏ត្រូវទទួលរងការវាយប្រហារដោយពាក្យសំដីនៅក្នុងអង្គប្រជុំសាធារណៈដោយអនុប្រធានមន្ទីរម្នាក់គំរាមអោយបិទអង្គការ ។ ជាលទ្ធផលទង្វើបែបនេះបានបង្ករអោយមានការស្ទាក់ស្ទើរនឹងភ័យខ្លាច គួរអោយកត់សំគាល់ក្នុងការពាក់ព័ន្ធជាមួយនឹងការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងនាមសមាជិកសហគមន៍ និងប៉ូលីសក្នុងមូលដ្ឋាន ។

**២០០៣ មករា:** ថ្មីៗក្រោយពីកុបកម្មប្រឆាំងថៃ ការវាយបំបែកលើការជួបជុំគ្នា និងបាតុកម្មបានកើតឡើង ។ ការហាមប្រាមដែលពីដើមពុំសូវមាន ពេលនោះបែរជាមានជាប្រចាំ ។ ក្រោយពីការបដិសេធមិនអនុញ្ញាតអោយជួបជុំគ្នា ការហាមប្រាមត្រូវបានជ្រើសរើសយកមកអនុវត្តន៍ ដូច្នេះរាល់ការជួប

ជុំរបស់អ្នកគាំទ្រគណៈបក្សប្រឆាំង និងបាតុកម្ម ដោយក្រុមផ្សេងៗត្រូវបានបដិសេធមិនអោយធ្វើឡើយ ។ ទង្វើនេះជាការរំលោភលើសិទ្ធិមនុស្ស និងកាតព្វកិច្ចស្របតាមរដ្ឋធម្មនុញ្ញ ដែលអនុញ្ញាតអោយមានសេរីភាពក្នុងការជួបជុំគ្នាដោយសន្តិវិធី និងសេរីភាពនៃការបញ្ចេញមតិ ។ ការប្រើប្រាស់កំលាំងហួសហេតុចាប់តាំងពេលនោះមកត្រូវបានប្រើប្រាស់ជាប្រចាំដើម្បីបំបែកការជួបជុំគ្នាដោយអហិង្សា ។ ផលវិបាកគឺអ្នកការពារសិទ្ធិមនុស្ស និងពលរដ្ឋសាមញ្ញយល់ថាការចូលរួមបាតុកម្ម និងឃ្លាំមើលជាការងាយរងគ្រោះថ្នាក់បំផុតមានការភ័យខ្លាចអំពើហិង្សា និងការចាប់ចងដោយត្រូវចោទប្រកាន់ថាបានការចូលរួម ឬបានញុះញង់ ។

**២០០៣ មិនា:** ការសំភាសន៏ជាមួយអង្គការអាហ្វេស៊ីប និងអង្គការមួយចំនួនដែលធ្វើការប្រឆាំង នឹងការជួញដូរមនុស្សបានបង្ហាញអោយឃើញថា ការគំរាមកំហែងនៅតែមានជាបន្តមកលើបុគ្គលិករួមមានការគំរាមតាមរយៈលិខិតតាមទូរស័ព្ទ ការគំរាមបុគ្គលិកផ្ទាល់ និងការគំរាម ដល់គ្រួសាររបស់បុគ្គលិកទាំងនោះ ។ ពេលដែលស៊ើបអង្កេតឃើញថា គេបានជួលមនុស្ស ដើម្បីលបលួចសំលាប់រួចហើយបុគ្គលិកដែលអាចរងគ្រោះនោះត្រូវបានបញ្ជូនទៅផ្ទះរបស់គេ ដើម្បីអោយមានសុវត្ថិភាព ។ គេបានសង្ស័យថា មន្ត្រីតុលាការ និងប៉ូលីសមានការពាក់ព័ន្ធនឹងជនល្មើសជួញដូរមនុស្ស ក៏ដូចជាគំរាមចោទប្រកាន់អង្គការពីបទផ្តល់កន្លែងស្នាក់នៅដល់ជនអន្តោប្រវេសន្តខុសច្បាប់ ឬពីបទឃុំឃាំងអនីតិជនពីព្រោះអង្គការទាំងនោះបានផ្តល់កន្លែងស្នាក់នៅដល់ស្ត្រី និងកុមារីដែលរំដោះបាន ។ ប្រធានអង្គការម្នាក់ត្រូវបានគេគំរាមដាក់គុកតាមទូរស័ព្ទ ប្រសិនបើជនរងគ្រោះ ដែលរំដោះមកនោះមិនព្រមដកពាក្យបណ្តឹងវិញ ។

**២០០៣ មេសា:** រដ្ឋាភិបាលបានបញ្ចប់កិច្ចសន្យាការត្រួតពិនិត្យព្រៃឈើរបស់គ្លូបូលវីតណេស ។

**២០០៣ ឧសភា :** រដ្ឋាភិបាលបានបដិសេធដោយមិនអនុញ្ញាតអោយក្រុមជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារជួបជុំប្រមូលផ្តុំគ្នាដោយសន្តិវិធី ដើម្បីជ្រើសរើសតំណាងរបស់ពួកគេអោយទៅចូលរួមជជែកពិភាក្សាស្តីពីពង្រាងច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារក្នុងរដ្ឋសភា ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឆ្លើយតបថា **"ប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម"** នេះបើតាមសំដីអះអាង របស់អភិបាលក្រុងភ្នំពេញ ក្នុងលិខិតឆ្លើយតបមួយ ។

**មិថុនា ២០០៣ :** រដ្ឋាភិបាលបានបដិសេធមិនអនុញ្ញាតអោយដល់សំណើសុំការដើរជាក្បួនដើម្បីអបអរទិវាបរិស្ថានពិភពលោក ។

**២០០៣ មិថុនា:** អធិការប៉ូលីសម្នាក់ និងមន្ត្រីប៉ូលីសជាច្រើននាក់ទៀតដែលបំពាក់ដោយកាំភ្លើងយន្តបានបំភិត

បំភ័យដល់បុគ្គលិកលីកាដូ និងបុគ្គលិកអង្គការសហប្រជាជាតិក្នុងជំលោះអំពីការចែកចាយសំភារៈបោះឆ្នោតនៅខេត្តបាត់ដំបង ។ គេបានថតរូបអ្នកការពារសិទ្ធិមនុស្សទាំងនោះ ដើម្បីបំភិតបំភ័យ ។ អ្នកការពារសិទ្ធិមនុស្សទាំងនោះបានចាកចេញដើម្បីជៀសវាងការប្រឈមមុខតទៅទៀត ។

**២០០៣ កក្កដា:** តុលាការខេត្តបាត់ដំបងកាត់ទោសកំបាំងមុខតំណាងសហគមន៍នេសាទ ៧នាក់ ។ ម្នាក់ៗត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល៣ឆ្នាំនឹងសងជំងឺចិត្តជាទឹកប្រាក់ចំនួន ៤០លាន រៀល ។ តុលាការធ្វើការសំរេចចិត្តដោយផ្អែកលើរបាយការណ៍របស់ប៉ូលីស និងឈ្មួញដែលប្តឹងទាមទារសំណងជាលុយកាក់តែប៉ុណ្ណោះ ។ តំណាងជលផលបានរឹបអូសដោយស្របច្បាប់នូវឧបករណ៍នេសាទរបស់ឈ្មួញ នោះដែលបានដឹកនាំការនេសាទខុសច្បាប់នៅក្នុងដែននេសាទ ដែលរដ្ឋបានបំរុងទុកសំរាប់ប្រជាជន ។ ការប្តឹងឧទ្ធរណ៍របស់ក្រុមអ្នកនេសាទបានជោគជ័យត្រឹមតែបន្ថយទោសប៉ុណ្ណោះមិនបានលើកលែងទាំងស្រុងទេ ។ ចុងចោទទាំងនោះស្ថិត នៅក្រៅមន្ទីរឃុំឃាំងក្រោមការដោះលែងអោយនៅក្រៅឃុំរង់ចាំប្តឹងទៅឧទ្ធរណ៍នៅសាលាក្តីកំពូលទៀត ។

**២០០៣ កក្កដា:** សមាជិកក្រុមប្រឹក្សាឃុំក្នុងស្រុកក្រូចឆ្មារខាងគណបក្សប្រជាជនម្នាក់បំភិតបំភ័យសមាជិកបណ្តាញជាន់ខ្ពស់ខុមហ្វ្រែលមួយចំនួនជាការប៉ុនប៉ង ដើម្បីរារាំងខុមហ្វ្រែលពីការជួលវីដេអូបញ្ចាំងការហ្វឹកហ្វឺនអំពីនីតិវិធីសង្កេតការការបោះឆ្នោត ។ ម្ចាស់វីដេអូក៏ត្រូវរងការបំភិតបំភ័យផងដែរ ។